ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍
សើស្បែក និង កាមរោគ
លេខ.១៣.៨៧មជអសក

រាជធានីភ្នំពេញ ថ្ងៃទី២០.. ខែ..ធ្នូ..... ឆ្នាំ ២០១២

cab
27/12/12

27 12 12
2870

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ**

**សូមគោរពជូន**

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល

**កម្មវត្ថុ:** សំណើសុំការឯកភាពលើក្របខ័ណ្ឌនៃគោលគំនិតដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើខ្ញុំបាទសូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តា ជ្រាបថា មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ សហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា បានរៀបចំបង្កើតឡើងនូវ ក្របខ័ណ្ឌនៃគោលគំនិតដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១២ ក្នុងគោលបំណងដើម្បីឈានទៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅក្នុងប្រទេសកម្ពុជា នៅឆ្នាំ ២០២០ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាពិនិត្យ និងសំរេចដោយអនុគ្រោះ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

វេជ្ជ. មាន_ឈីវុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ក្របខ័ណ្ឌនៃគោលគំនិតដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០២០

ខែ ធ្នូ ឆ្នាំ ២០១២

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

# មាតិកា


អារម្ភកថា ..........................................................................................

ថ្លែងអំណរគុណ .................................................................................... ៤

១. សេចក្តីផ្តើម ..................................................................................... ៥

២. សនិទានភាព....................................................................................... ៦

២.១. និន្នាការនៃអត្រាប្រវ៉ាឡង់និងអាំងស៊ីដង់នៃការឆ្លងមេរោគអេដស៍ ............................. ៦

២.២. ការរៀបចំយុទ្ធវិធីកម្ពុជា៣.០ ផ្អែកលើការឆ្លើយតបប្រកបដោយជោគជ័យ (Building on successful responses).............................................................. ៧

៣. គោលបំណង និងកម្មវត្ថុ( Goals and Objectives)............................................ ១០

៤. គោលការណ៍គន្លឹះ និងវិធីសាស្ត្រសំរាប់អនុវត្តកម្មវិធី ( Key Principles and Programmatic Strategies ) ................................................ ១២

៤.១ យុទ្ធវិធីសំរាប់អនុវត្តកម្មវិធី សំខាន់ៗមានដូចខាងក្រោម: ......................................... ១២

៥. ព័ត៌មានជាយុទ្ធសាស្ត្រ ........................................................................... ១៥

៥.១. ការអង្កេតតាមដាន និងការសិក្សាស្រាវជ្រាវ ............................................... ១៦

៥.២. របាយការណ៍នៃករណីឆ្លងមេរោគអេដស៍ ..................................................... ១៨

៥.៣. ការតាមដានកម្មវិធីជាប្រចាំសំរាប់យុទ្ធវិធីនិមួយៗ.............................................. ១៨

៥.៤. ការធ្វើគំរូបែបគណិតវិទ្យា ...................................................................... ២០

៥.៥. ការធ្វើផែនការ និងការវាយតំលៃ ............................................................. ២១

៦. សម្មតិកម្មទាក់ទងនឹងការអនុវត្តន៍កម្មវិធី (Programmatic assumptions) ....................... ២១

៧ ការគ្រប់គ្រងកម្មវិធី ................................................................................ ២១

៧.១ ក្រុមស្នូលនៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ ......................................... ២១

៧.២ អនុក្រុមនៃយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថែទាំ ព្យាបាលបន្ត ចំពោះក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (Boosted CoPCT)........................................ ២២

៧.៣ អនុក្រុមនៃយុទ្ធវិធីជំរុញខ្លាំងក្លាការឆ្លើយតបរួមគ្នា រវាងសេវាថៃទាំព្យាបាលជំងឺអេដស៍ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងជំងឺរបេង ដើម្បីការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ លើកុមារ និងជំងឺស្វាយ ពីកំណើត នៅប្រទេសកម្ពុជា ...................... ២២
៧.៤ អនុក្រុមនៃការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ជាមធ្យោបាយដើម្បីបង្ការការចំលងមេរោគអេដស៍ ........................................................................ ២២
៧.៥ អនុក្រុមនៃព័ត៌មានជាយុទ្ធសាស្រ្ត ........................................................................ ២៣
**៨. ផែនទីបង្ហាញផ្លូវ** ........................................................................ ២៣

# អារម្ភកថា

នៅទសវត្ស ១៩៩០ (ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ២០០០) ការឆ្លងរាលដាលនៃមេរោគអេដស៍បានកើនឡើងយ៉ាងឆាប់រហ័សឈានដល់ចំណុចខ្ពស់បំផុតនៅឆ្នាំ ១៩៩៨ ដែលមានអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅអាយុលើសពី១៥ឆ្នាំ ប្រមាណ ១,៧% ហើយបានចាប់ផ្តើមថយចុះជាបន្តបន្ទាប់។ ក្នុងស្ថានភាពអេពីដេមីនៃការរាលដាលមេរោគអេដស៍នេះគ្រប់ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ រួមមានម្ចាស់ជំនួយ, អង្គការសហប្រជាជាតិ, សង្គមស៊ីវិលបានសហការយ៉ាងស្អិតរមួតខិតខំប្រឹងប្រែងទប់ស្កាត់ការរាលដាលនៃមេរោគនេះ ដោយផ្តោតលើការអប់រំ, ការបង្ការ, ជាពិសេស ការផ្លាស់ប្តូរការប្រព្រឹត្តផ្លូវភេទដែលគ្មានសុវត្ថិភាព និងកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០%។ គំនិតផ្តួចផ្តើម និងវិធីសាស្ត្រនានានៅទសវត្សទីមួយនៃការឆ្លងរាលដាលមេរោគអេដស៍នេះ គឺជាដំណាក់កាល " កម្ពុជា ១.០ "។

នាទសវត្សរ៍ឆ្នាំ២០០០ (ពីឆ្នាំ ២០០១-២០១០) ក្រសួងសុខាភិបាលដែលមានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ជាសេនាធិការ បានអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់នូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលលើវិស័យសុខាភិបាលដែលរួមមាន ការបង្ការការថែទាំ និងព្យាបាលជំងឺអេដស៍ផងដែរ។ នៅដំណាក់កាលនេះ យុទ្ធវិធីនិងវិធីសាស្ត្រយ៉ាងច្រើនបានរៀបចំជាពិសេសវិធីសាស្ត្រថែទាំព្យាបាលបន្ត (Continuum of Care) សំរាប់ជំងឺអេដស៍បានចាប់ផ្តើមអនុវត្តនៅថ្នាក់ស្រុកប្រតិបត្តិនា ឆ្នាំ ២០០៣ ហើយបានពង្រីកជាបន្តបន្ទាប់ ដោយទទួលបានជោគជ័យក្នុងការផ្តល់ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ដល់អ្នកជំងឺលើសពី៥០% ដែលទទួលបាននូវពានរង្វាន់កោតសរសើរពីអង្គការសុខភាពពិភពលោក។ ទន្ទឹមនឹងនេះ ការបង្កើននូវអត្រាគ្របដណ្តប់នៃការធ្វើតេស្តឈាមរកមេរោគអេដស៍ និងមេរោគស្វាយ ក្នុងចំណោមប្រជាជនដែលប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍(MARP), ស្ត្រីមានផ្ទៃពោះ, អ្នកជំងឺរបេង, អ្នកជំងឺកាមរោគតាមរយៈការអនុវត្តន៍វិធីសាស្ត្រ CoPCT, វិធីសាស្ត្រឆ្លើយតបរួមគ្នា, យុទ្ធសាស្ត្រ 3Is និងឯកសារគោលគំនិតក្នុងការធ្វើតេស្តឈាមរកមេរោគស្វាយក្នុងចំណោមស្ត្រី មានផ្ទៃពោះពីឆ្នាំ២០១០ ទៅ២០១៥ នៅប្រទេសកម្ពុជា។

ផ្អែកលើគំនិតផ្តួចផ្តើមថ្មីៗជាសកលរបស់អង្គការសហប្រជាជាតិ មានជាអាទិ៍ យុទ្ធសាស្ត្រ Three Zero និង "កម្ពុជា ២.០ " មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍ បានរៀបចំចងក្រងឯកសារសំខាន់ៗ សំរាប់ជាមាគ៌ាយុទ្ធសាស្ត្រតំរង់ទិសឆ្ពោះទៅសំរេចបានដោយជោគជ័យនូវគំនិតផ្តួចផ្តើម "កម្ពុជា៣.0" (Cambodia 3.0) ដើម្បីឈានទៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០២០។

ក្រសួងសុខាភិបាលឯកភាពជាផ្លូវការ ដាក់ឲ្យអនុវត្តនូវឯកសារក្របខ័ណ្ឌគោលគំនិតសំរាប់ជាមាគ៌ាយុទ្ធសាស្ត្រ តំរង់ទិសឆ្ពោះទៅសំរេចបានដោយជោគជ័យនូវគំនិតផ្តួចផ្តើម "កម្ពុជា៣.០" ហើយសង្ឃឹមថា មន្ត្រីសុខាភិបាល ដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ ម្ចាស់ជំនួយ និងសង្គមស៊ីវិលទាំងអស់នឹងអនុវត្តតាមឯកសារក្របខ័ណ្ឌគោលគំនិតនេះ ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០២០។

ភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

# ថ្លែងអំណរគុណ

ក្របខ័ណ្ឌនៃគោលគំនិតដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០២០ គឺជាឯកសារដ៏មានសារៈសំខាន់ និងជាមាគ៌ាបង្ហាញនូវយុទ្ធវិធីគន្លឹះនានា ព្រមទាំងកញ្ចប់សកម្មភាពជាអាទិភាពដែលប្រើប្រាស់ធនធានតិច ហើយទទួលបានលទ្ធផលច្រើន និងប្រកបដោយគុណភាព។ ការចងក្រងឯកសារនេះ បានបញ្ចប់ជាស្ថាពរក្នុងរយៈពេលខ្លី គឺដោយសារការខិតខំប្រឹងប្រែងមិនចេះនឿយហត់របស់ក្រុមការងារជំនាញ ដែលរួមមានមន្ត្រីនៃមជ្ឈ មណ្ឌលប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ, មន្ត្រីនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និង ទារក មន្ត្រីនៃមជ្ឈមណ្ឌលជាតិកំចាត់រោគរបេងនិងហង់សិន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ក្នុងនោះ មាន អង្គការសុខភាពពិភពលោក (WHO), អង្គការ UNICEF, UNAIDS, US-CDC, USAID, CHAI, KHANA, FHI 360, RHAC, PSI និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ដែលមិនបានរៀបរាប់ ឈ្មោះខាងលើនេះ។

តាងនាមមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោក-លោកស្រីទាំងអស់ជាសមាជិក-សមាជិកានៃក្រុមការងារជំនាញ និងដៃគូអភិវឌ្ឍន៍នានា ដែលចំណាយពេលដ៏មានតំលៃក្នុងការផ្តល់មតិយោបល់, បទពិសោធន៍ទាំងក្នុងប្រទេស, បណ្តាប្រទេសក្នុងតំបន់ និងសកលលោកផងដែរ។

មជ្ឈមណ្ឌលជាតិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះក្រសួងសុខាភិបាលជាពិសេស ឯកឧត្តមរដ្ឋមន្ត្រី ដែលបានគាំទ្រយ៉ាងពេញទំហឹងទាំងផ្នែកនយោបាយ និងគោលនយោ បាយ ព្រមទាំងអនុសាសន៍ប្រកបដោយគតិបណ្ឌិត ក្នុងការបង្ការថែទាំ និងព្យាបាលជំងឺអេដស៍ ចាប់ពីពេលរកឃើញអ្នកផ្ទុកមេរោគអេដស៍ នៅទសវត្ស ១៩៩០ កន្លងមក។

ភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២

វេជ្ជ. មាន_ឈីវុន

# ក្របខ័ណ្ឌនៃគោលគំនិតដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០២០ ("Cambodia 3.0")

## ១. សេចក្តីផ្តើម

នាពាក់កណ្តាលទសវត្ស ១៩៩០, ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានការរាលដាលនៃមេរោគអេដស៍យ៉ាងលឿនបំផុតនៅក្នុងបណ្តាប្រទេសក្នុងទ្វីបអាស៊ី។ នៅក្នុងកំឡុងពេល៥ឆ្នាំ ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសមួយចំនួនតូចដែលសំរេចបានជោគជ័យ ក្នុងការកាត់បន្ថយការឆ្លងរាលដាលមេរោគអេដស៍។ នៅឆ្នាំ២០១០, ព្រះរាជាណាចក្រកម្ពុជា បានទទួលការកោតសរសើរ (ពានរង្វាន់) ក្នុងការសំរេចបាននូវគោលដៅអភិវឌ្ឍន៍ សហស្សវត្ស (MDG6-HIV) ពីអង្គការសហប្រជាជាតិដែលបានទទួលស្គាល់ ជាសកលអំពីការខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ពី១,៧% (ក្នុងចំណោមមនុស្សពេញវ័យអាយុពី១៥ទៅ៤៩ឆ្នាំ) នៅឆ្នាំ១៩៩៨ មក០,៧% នៅឆ្នាំ២០១១ ព្រមទាំងសំរេចបាន ផងដែរក្នុងការផ្តល់សេវាថែទាំនិងព្យាបាលបន្ត ជាពិសេសការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ជូន អ្នកជំងឺអេដស៍លើសពី៨០%។

នៅក្នុងកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិ (UN General Assembly High Level Meeting) អំពីជំងឺអេដស៍ នៅទីក្រុងញូវយ៉កនៅខែមិថុនាឆ្នាំ២០១១, ព្រះរាជាណាចក្រកម្ពុជាបានសំដែងនូវការប្តេជ្ញាចិត្តដើម្បីសំរេចគោលដៅរួមនិងទិសដៅនៃការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាក្នុងការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍។ ផ្អែកលើគំនិតផ្តួចផ្តើមថ្មីៗជាសកលរបស់អង្គការសហប្រជាជាតិមានជាអាទិ៍ យុទ្ធសាស្រ្ត "Three Zeros" និង "ការព្យាបាល ២.០", មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍និងកាមរោគនៃក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍បាន និងកំពុងរៀបចំចងក្រងឯកសារសំខាន់ៗ ចំនួនប្រាំបីសំរាប់ជាមាគ៌ាយុទ្ធសាស្រ្តតំរង់ទិសឆ្ពោះទៅសំរេចបានដោយជោគជ័យនូវគំនិតផ្តួចផ្តើមកម្ពុជា៣.0 (Cambodia3.0) ដើម្បីឈានទៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ២០២០។

ឯកសារគោលគំនិតនេះ បានបង្ហាញពីលទ្ធផលដែលសំរេចបានមកដល់បច្ចុប្បន្ននេះ ព្រមទាំងចង្អុលបង្ហាញពីយុទ្ធវិធីឈានទៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃការឆ្លើយតបរបស់វិស័យសុខាភិបាលដើម្បីឈានទៅសំរេចយុទ្ធសាស្រ្ត "Three Zeros" ។ ដើម្បីឈានទៅសំរេចបាននូវ គោលដៅ *គ្មានការឆ្លងថ្មីនៃមេរោគអេដស៍*,និងស្របជាមួយគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០១២[1],ក្រុមអ្នកជំនាញជាតិនិងអន្តរជាតិបានសិក្សានិង វិភាគលើយុទ្ធវិធី និងវិធីសាស្រ្តព្រមទាំងគំរូអន្តរាគមន៍ដែលជំរុញឲ្យមានការ

---

[1] គោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោកឆ្នាំ២០១២ អំពី *ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគ ដល់ដៃគូ រួមបញ្ចូលទាំងការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ សំរាប់ព្យាបាលនិងការបង្ការដល់ដៃគូ ណាដែលមានលទ្ធផលតេស្តវិជ្ជមានតែម្នាក់, និងធ្វើបច្ចុប្បន្នភាពនៃកម្មវិធីៈ ប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍សំរាប់ព្យាបាលស្រ្តីមានផ្ទៃពោះ និងការព្យាបាលបង្ការការឆ្លងមេរោគអេដស៍ដល់កុមារផងដែរ, ព្រមទាំងការព្យាបាលដើម្បីបង្ការ ដូចដែលមានការជជែកពិភាក្សានៅលើពិភពលោកពេលថ្មីៗនេះ។*

បង្កើនការស្រាវជ្រាវរកករណីជំងឺអេដស៍ក្នុងចំណោមប្រជាជនដែលប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (MARP), ស្ត្រីមានផ្ទៃពោះ, និងដៃគូរបស់អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេស៍ដែលកំពុងទទួលសេវាថែទាំនិងព្យាបាលបន្ត និងបានចាប់ផ្តើមភ្លាមៗ ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ភ្លាមៗ ដើម្បីបង្ការការចំលងមេរោគអេដស៍។

ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅប្រទេសកម្ពុជា, យុទ្ធវិធីជំរុញខ្លាំងក្លានៃអន្តរាគមន៍បង្ការ ថៃទាំនិងព្យាបាលជំងឺអេដស៍និងជំងឺកាមរោគ (Boosted CoPCT) ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (MARP) បានក្លាយជាយុទ្ធសាស្ត្រជាអាទិភាព។ អត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមក្រុម MARP នៅមានកំរិតខ្ពស់នៅឡើយ, ទោះបីជាមានការថយចុះនូវការឆ្លងរាលដាលមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅក៏ដោយ។ លទ្ធផលនៃការសិក្សា(cross sectional study) លើក្រុមអ្នកចាក់គ្រឿងញៀន(PWID) ដោយNCHADS នៅឆ្នាំ២០០៧ បានបង្ហាញថា អត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍មានប្រមាណ២៤.៤%[2]។ ដូចគ្នានេះដែរ, របាយករណ៍របស់គ្លីនិកព្យាបាលអ្នកចាក់គ្រឿងញៀន ដោយប្រើមេតាដូន(MMT)នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានបង្ហាញថា ២៤% នៃអ្នកចាក់គ្រឿងញៀន ចំនួន ១៨៧នាក់[3]មានផ្ទុកមេរោគអេដស៍។ អត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមស្ត្រីបំរើសេវាកំសាន្តសប្បាយ (FEW) ដែលបានរាយការណ៍ថា បានរួមភេទជាមួយអតិថិជនលើសពី១៤នាក់ក្នុងមួយសប្តាហ៍ គឺមាន១៣,៩%, ឬបានរួមភេទជាមួយអតិថិជន ១៤នាក់ឬតិចជាងនេះ គឺមានត្រឹមតែ៤,១%[4]ប៉ុណ្ណោះ។ ជំងឺកាមរោគនៅតែជាបញ្ហាសុខភាពសាធារណៈដ៏ចំបងក្នុងចំណោមក្រុមប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ខ្ពស់។ លទ្ធផលជាបឋមនៃការអង្កេតតាមដានជំងឺកាមរោគ (SSS) នៅឆ្នាំ២០១១ បានបង្ហាញថា ក្នុងចំណោមស្ត្រីបំរើសេវាកំសាន្តសប្បាយ (ស្ត្រីបំរើសេវាផ្លូវភេទនិងស្ត្រីខារ៉ាអូខេ) អត្រាប្រេវ៉ាឡង់នៃការឆ្លងជំងឺក្លាមីឌីយ៉ា(chlamydia) មាន ២៤%, ជំងឺប្រមេះ(gonorrhea) មាន ៩,៤%, និងជំងឺស្វាយ មាន ០,៩៤%។ រីឯ ការសិក្សាអំពីប្រុសខ្មែររកឃើញថា អត្រាប្រេវ៉ាឡង់នៃការឆ្លងជំងឺកាមរោគក្នុងចំណោមបុរសស្រឡាញ់បុរសដែលបំរើការនៅតាមដំបន់ដែលមានការឆ្លងមេរោគអេដស៍ខ្ពស់(តំបន់ក្តៅ)មាន ២.២%។ អន្តរាគមន៍នានាត្រូវផ្តោតលើក្រុមទាំងអស់នេះ គឺជាយុទ្ធសាស្ត្រគន្លឹះដើម្បីឈានទៅសំរេច បាននូវគោលបំណងនៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅប្រទេសកម្ពុជា នៅឆ្នាំ ២០២០។

# ២. សនិទានភាព

## ២.១. និន្នាការនៃអត្រាប្រេវ៉ាឡង់និងអាំងស៊ីដង់នៃការឆ្លងមេរោគអេដស៍

ការប៉ាន់ស្មាននិងការព្យាករណ៍អំពីការឆ្លងមេរោគអេដស៍ នាឆ្នាំ២០១១, បានបង្ហាញថាការឆ្លងថ្មីនៃមេរោគអេដស៍បានថយចុះយ៉ាងលឿនបន្ទាប់ពីឡើងដល់កំពូលដែលមានចំនួន២០ ៩៧៨នាក់នៅឆ្នាំ២០០៥ នឹងចុះមកត្រឹម ១ ៧៨០នាក់នៅឆ្នាំ២០១០ និង ១.០០៧ នៅឆ្នាំ ២០១៥ (រូបភាពទី១)។

[2] NCHADS (2007). HIV Prevalence Survey Among Drug Users.
[3] Center for Mental Health and Drug Dependence (2012). Preliminary Results of MMT in Cambodia, from 1st July 2010 to 30th June 2012.
[4] NCHADS (2011). Estimations and Projections of HIV/AIDS in Cambodia 2010-2015.

## រូបភាពទី១.   ការព្យាករណ៍ចំនួនករណីឆ្លងថ្មីនៃមេរោគអេដស៍ និងចំនួនអ្នករស់នៅជាមួយមេរោគអេដស៍




ប្រភព: NCHADS (២០១១). ការប៉ាន់ស្មាននិងការព្យាករណ៍នៃការឆ្លងមេរោគអេដស៍និងជំងឺអេដស៍នៅប្រ ទេសកម្ពុជាពីឆ្នាំ ២០០០-២០១៥

## ២.២.   ការរៀបចំយុទ្ធវិធីកម្ពុជា៣.០ ផ្អែកលើការឆ្លើយតបប្រកបដោយជោគជ័យ (Building on successful responses)

យុទ្ធវិធីកម្ពុជា៣.០ បានរៀបចំឡើងដោយផ្អែកលើគំនិតផ្តួចផ្តើមថ្មីៗប្រកបដោយជោគជ័យ មានដូចខាង ក្រោម៖

### ២.២.១ ការបង្ការការចំលងមេរោគអេដស៍ដោយផ្តោតលើក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (MARPs)

ជោគជ័យនៃកម្មវិធីប្រើប្រាស់ស្រោមអនាម័យ១០០%  ដែលបានអនុវត្តលើស្ត្រីរកផ្លូវភេទនៅតាមផ្ទះបនត្រូវបានធ្វើការកែសំរួលដើម្បីគ្របដណ្តប់ដល់ស្ត្រីដែលបំរើសេវាផ្លូវភេទ 'ដោយប្រយោល' ឧទាហរណ៍ស្ត្រីបំរើការនៅខារ៉ាអូខេ, ម៉ាស្សា, បៀរហ្គាឌិន,ស្ត្រីឡង់សេស្រាបៀរ, Freelancers។ ចាប់តាំងពីចុងទសវត្ស២០០០ (ឆ្នាំ២០០៩), ការកែសំរួលកម្មវិធីនេះរួមមាន អន្តរាគមន៍នៃការចុះអប់រំផ្ទាល់ដោយមិត្តអប់រំមិត្តចំពោះ "ស្ត្រីបំរើសេវាកំសាន្តសប្បាយ" ដោយផ្សាភ្ជាប់ការអប់រំទៅនឹងការទទួលបានសេវាថែទាំព្យាបាលបន្ត ក្នុងនោះសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍និងរកមេរោគស្វាយ, ពិនិត្យនិងព្យាបាលជំងឺកាមរោគ និងសេវា Pre-ART/ART ចំពោះអ្នកផ្ទុកមេរោគអេដស៍។ វិធីសាស្រ្តបច្ចុប្បន្នហៅថា "វិធីសាស្រ្តបង្ការថែទាំនិងព្យាបាលបន្ត ( Continuum of HIV Prevention to Care and Treatment "COPCT") ។ ទោះបីជាមានការបែងចែកស្ត្រីបំរើសេវាផ្លូវភេទជាច្រើនប្រភេទតាំងពីឆ្នាំ២០០៨ និងនិយមន័យនៃប្រភេទស្ត្រីរកស៊ីផ្លូវភេទដែលមានការវិវត្តន៍តាំងពីឆ្នាំ២០០៧ក៏ដោយ, ក៏ការប្រើប្រាស់ស្រោមអនាម័យជាប់ជានិច្ចជាមួយនឹងអតិថិជននៅតែស្ថិតក្នុងកំរិតខ្ពស់ជាង៨០%ដដែល។ ការតាមដាននិន្នាការនៃអត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ចាប់តាំងពីចុងទសវត្ស២០០០ បង្ហាញពីបញ្ហាប្រឈមចំបងៗដូចបានឃើញក្នុងរូបភាពទី២ខាងក្រោមនេះ។

រូបភាពទី២. អត្រាប្រេវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមស្ត្រីបំរើសេវាផ្លូវភេទ (FSW), ធៀបជាមួយនឹងស្ត្រីបំរើសេវាកំសាន្តសប្បាយ (FEW) ដែលរួមភេទជាមួយអតិថិជនចាប់ពី ១៥ នាក់ឡើងទៅក្នុងមួយសប្តាហ៍




ប្រភព: NCHADS (២០១១). ការប៉ាន់ស្មាននិងការព្យាករណ៍នៃការឆ្លងមេរោគអេដស៍និងជំងឺអេស៍នៅប្រទេសកម្ពុជាពីឆ្នាំ ២០០០-២០១៥

វិធីសាស្ត្រ COPCT ត្រូវបានអនុវត្តលើក្រុមបុរសស្រឡាញ់បុរស, ក្រុមTG និង ក្រុមអ្នកចាក់គ្រឿងញៀនផងដែរ។ កម្មវិធីម្ជុលសឺរ៉ាំងនិងការព្យាបាលជំនួសដោយមេតាដូនលើក្រុមអ្នកចាក់គ្រឿងញៀនត្រូវបានអនុវត្តនៅឆ្នាំ២០១០។ ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអដស៍ (ការផ្តល់ប្រឹក្សានិងការធ្វើតេស្តឈាមរកមេរោគអេដស៍ ដែលផ្តួចផ្តើមដោយសហគមន៍/មិត្តអប់រំមិត្តៈCPITC) ត្រូវបានពង្រីកនៅខែមេសាឆ្នាំ២០១១ ដោយផ្តោតលើក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍។

### ២.២.២ វិធីសាស្ត្រឆ្លើយតបរួមគ្នាសំរាប់គាំទ្រសេវា PMTCT

ការផ្សាភ្ជាប់មានលក្ខណៈជាប្រព័ន្ធរវាងសេវាថែទាំនិងព្យាបាលជំងឺអេដស៍ និងសេវាសុខភាពបន្តពូជ (*វិធីសាស្ត្រឆ្លើយតបរួមគ្នា*) បានរួមចំណែកដ៏ធំធេងក្នុងការពង្រីកសេវាPMTCT។ អត្រាគ្របដណ្តប់នៃការធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះបានកើនឡើងពី២៩% នៅឆ្នាំ២០០៨ ដល់៧៨% នៅឆ្នាំ២០១១ និងអត្រាគ្របដណ្តប់ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថARV សំរាប់បង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូនបានកើនឡើងពី២៧% នៅឆ្នាំ២០០៨ទៅ ៦៤%នៅឆ្នាំ២០១១។ ជាលទ្ធផល, ចំនួននៃករណីឆ្លងមេរោគអេដស៍ថ្មីក្នុងចំណោមកុមារ និងអត្រានៃការចំលងមេរោគអេដស៍ពីម្តាយទៅកូនបានថយចុះយ៉ាងខ្លាំងជាបន្តបន្ទាប់ (សូមមើលរូបភាពទី៣និងទី៤)។

### រូបភាពទី៣. ចំនួនករណីថ្មីនៃការឆ្លងមេរោគអេដស៍ ក្នុងចំណោមកុមារអាយុក្រោម១៤ឆ្នាំ ,២០០០-២០១៥ (Spectrum)




ប្រភព: NCHADS (២០១១). ការប៉ាន់ស្មាននិងការព្យាករណ៍នៃការឆ្លងមេរោគអេដស៍និងជំងឺអេដស៍នៅប្រទេសកម្ពុជាពីឆ្នាំ ២០០០-២០១៥

### រូបភាពទី៤. ការព្យាករណ៍អត្រានៃការចំលងមេរោគអេដស៍ពីម្តាយទៅកូន, ២០០០-២០១៥ (Spectrum)




ប្រភព: NCHADS (២០១១). ការប៉ាន់ស្មាននិងការព្យាករណ៍នៃការឆ្លងមេរោគអេដស៍និងជំងឺអេដស៍នៅប្រទេសកម្ពុជាពីឆ្នាំ ២០០០-២០១៥

## ២.២.៣ ការពង្រីកសេវាថែទាំនិងព្យាបាលបន្ត

ការទទួលបានសេវាជាសកលនៃការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ អាចសំរេចបានគឺតាមរយៈការចូលរួមមានលក្ខណៈជាប្រព័ន្ធនិងការសំរបសំរួលជាមួយនឹងអាជ្ញធរមូលដ្ឋាន, មន្ត្រីសុខាភិបាល, អង្គការមិនមែនរដ្ឋាភិបាល, អ្នកផ្ទុកមេរោគអេដស៍និងអ្នកជំងឺអេដស៍ (តាមរយៈ MMM/mmm-មណ្ឌលមិត្តជួយមិត្ត) និងការបង្ការ ការថែទាំនិងការគាំទ្រដោយសហគមន៍ (រូបភាពទី៥)។ រចនាសម្ព័ន្ធនៃការថែទាំព្យាបាលបន្តគឺត្រូវបានពង្រឹង តាមរយៈការពង្រឹងគុណភាពបន្ត(CQI)[5] ដែលជាលទ្ធផលគឺ median នៃកោសិកាCD4 នៅកំរិតខ្ពស់ (២៥០កោសិកា/មម$^{៣}$) នៅពេលអតិថិជនបានមកចុះឈ្មោះនៅសេវា pre-ART និងអ្នកជំងឺមក

[5] CQI បានចាប់ផ្តើមអនុវត្តនៅសេវា Pre-ART/ART សំរាប់មនុស្សពេញវ័យចំនួន ២៧ដោយគិតត្រឹមត្រីមាសទី២ ឆ្នាំ២០១២។

ទទួលសេវាព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍បានជាប់ជានិច្ច (៧៨% នៅខែទី៦០ ក្រោយពេលចាប់ផ្តើម ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍)។

**រូបភាពទី៥. ចំនួនអ្នកផ្ទុកមេរោគអេដស៍, ដែលត្រូវការសេវាព្យាបាល និងបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ដែលមានអាយុពី១៥ឆ្នាំឡើងទៅ,ពីឆ្នាំ២០០០-២០១៥**




ប្រភព: NCHADS (២០១១). ការប៉ាន់ស្មាននិងការព្យាករណ៍អំពីការឆ្លងមេរោគអេដស៍និងជំងឺអេដស៍នៅប្រទេសកម្ពុជាពីឆ្នាំ ២០០០-២០១៥

## ៣. គោលបំណង និងកម្មវត្ថុ( Goals and Objectives)

អនុលោមតាមសេចក្តីប្រកាសស្តីពីនយោបាយប្រយុទ្ធនឹងការរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ (Political Declaration on HIV/AIDS) នៃកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិស្តីអំពីជំងឺអេដស៍ (UN General Assembly High Level Meeting on AIDS) នៅទីក្រុងញូវយ៉ក នាខែមិថុនាឆ្នាំ២០១១ ព្រះរាជាណាចក្រកម្ពុជាបានប្តេជ្ញាចិត្តខិតខំប្រឹងប្រែងអនុវត្តយុទ្ធវិធីឆ្ពោះទៅរកការលុបបំបាត់ការឆ្លងថ្មី នៃមេរោគអេដស៍និងជំងឺស្វាយពីកំណើត នៅឆ្នាំ២០២០។

ដើម្បីសំរេចបាននូវគោលបំណងខាងលើនេះ គំនិតផ្តួចផ្តើម "កម្ពុជា ៣.០" (Cambodia 3.0) មានបំណងសំរេចឲ្យបានកម្មវត្ថុដូចខាងក្រោម:

- សំរេចឲ្យបាននូវការទទួលបានជាសកលសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ និងមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ និងដៃគូរួមភេទរបស់ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍

- សំរេចឲ្យបាននូវការទទួលបានជាសកលនូវសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ និងជំងឺស្វាយចំពោះក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ និងដៃគូរួមភេទសំខាន់ៗ(ទៀងទាត់) របស់ពួកគេ។
- រៀបចំបង្កើតប្រព័ន្ធសំរាប់ផ្តល់សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ជូនដល់ដៃគូរួមភេទរបស់អ្នកជំងឺអេដស៍ដែលកំពុងទទួលសេវាថែទាំ pre-ART និង ART
- សមាហរណកម្មនៃការចាប់ផ្តើមភ្លាមៗ/ឆាប់រហ័សក្នុងការផ្តល់ការព្យាបាលដោយឱសថ ARV (immediate /early initiation of ART) ទៅក្នុងប្រព័ន្ធថៃទាំ និងព្យាបាលជំងឺអេដស៍ ។

ការវាស់ស្ពានភាពនៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ និងជំងឺស្វាយពីកំណើត នឹងត្រូវកំណត់ឡើងដោយផ្អែកទៅលើការរីកចំរើនថ្មីៗនៃគំនិតផ្តួចផ្តើម"សូន្យបី" និងការលុបបំបាត់ជំងឺស្វាយពីកំណើតរបស់សកលលោក ។ គោលបំណងសំខាន់ៗរួមមានៈ

- កាត់បន្ថយការប៉ាន់ស្មានអត្រាអាំងស៊ីដង់នៃការឆ្លងមេរោគអេដស៍ ក្នុងចំណោមប្រជាជនអាយុចាប់ពី១៥ឆ្នាំឡើងទៅពីកំរិត ១៨/១០០.០០០ នៅឆ្នាំ២០១០ មក ៣/១០០.០០០ ឬកំរិតទាបជាងនេះនៅឆ្នាំ២០២០ *(ការប៉ាន់ស្មាន និងការព្យាករណ៍ នៅឆ្នាំ ២០១១ លើអត្រាអាំងស៊ីដង់ សំរាប់ឆ្នាំ ២០២០គឺ ៥/១០០.០០០)*
- កាត់បន្ថយអត្រានៃការឆ្លងមេរោគអេដស៍ពីម្តាយ ទៅកូនពីកំរិត ១៣% នាឆ្នាំ ២០១០ មក ២%ឬកំរិតទាបជាងនេះ នៅឆ្នាំ២០២០[6]
- សំរេចឲ្យបានអត្រាគ្របដណ្តប់នៃការធ្វើតេស្តរកមេរោគស្វាយក្នុងកំរិតលើសពី ៩៥% លើស្ត្រីមានផ្ទៃពោះ និងអត្រាព្យាបាលសមស្របនៃជំងឺស្វាយក្នុងចំណោមស្ត្រីមានផ្ទៃពោះដែលមានលទ្ធផលតេស្តមេរោគស្វាយវិជ្ជមាន ក្នុងកំរិតលើសពី៩៥% នៅឆ្នាំ២០២០។[7]

---

[១] ទិសដៅរួមសំរាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិករួមមានៈ

- កាត់បន្ថយការឆ្លងថ្មីនៃមេរោគអេដស៍លើកុមារឲ្យបាន៩០% នាឆ្នាំ ២០១៥ (ពីកំរិតមូលដ្ឋាននាឆ្នាំ២០០៩)
- កាត់បន្ថយការចម្លងមេរោគអេដស៍ពីឪពុកម្តាយទៅកូនឲ្យនៅកំរិតតិចជាង ៥% (ពីកំរិតមូលដ្ឋាននាឆ្នាំ២០០៩)

(UNICEF, WHO, UNFPA, UNAIDS. Elimination of New Pediatric HIV Infections and Congenital Syphilis in Asia-Pacific, 2011-2015: Conceptual Framework and Monitoring and Evaluation Guide. Bangkok: UNICEF EAPRO, 2011)

[២] ទិសដៅសាកលលោកសំរាប់គំនិតផ្តួចផ្តើមស្តីពីការលុបបំបាត់ជំងឺស្វាយពីកំណើតគឺៈ

- ស្ត្រីមានផ្ទៃពោះយ៉ាងតិច៩០% នឹងត្រូវទទួលការធ្វើតេស្តរកមេរោគស្វាយនាឆ្នាំ២០១៥ និង
- ស្ត្រីមានផ្ទៃពោះដែលមានលទ្ធផលតេស្តជំងឺស្វាយ យ៉ាងតិច៩០% នឹងត្រូវទទួលការព្យាបាលសមស្របនាឆ្នាំ២០១៥។

(WHO. Methods for surveillance and monitoring of congenital syphilis elimination within existing systems. Geneva: WHO, 2011)

## ៤. គោលការណ៍គន្លឹះ និងវិធីសាស្រ្តសំរាប់អនុវត្តកម្មវិធី ( Key Principles and Programmatic Strategies )

ទិសដៅយុទ្ធសាស្រ្តរួមមានបីផ្នែកសំខាន់ៗ: (i) ការលុបបំបាត់ការចម្លងនៃមេរោគអេដស៍ និងជំងឺស្វាយពីម្តាយទៅកូន តាមរយៈយុទ្ធវិធីជំរុញខ្លាំងក្លាការអនុវត្តន៍វិធីសាស្រ្តឆ្លើយតបរួមគ្នា; (ii) ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ និងការបង្កើតប្រព័ន្ធទំនាក់ទំនងជាមួយសេវាថែទាំសុខភាពតាមរយៈយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថែទាំ ព្យាបាលបន្តចំពោះក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍; និង (iii) ការប្រើប្រាស់ការព្យាបាលដោយឱសថ ARV ជាមធ្យោបាយបង្ការការចម្លងមេរោគអេដស៍ (ART as Prevention) ដែល ជាផ្នែកមួយនៃយុទ្ធវិធីជំរុញខ្លាំងក្លាការថែទាំព្យាបាលបន្ត ។

### រូបភាពទី៦. ទិសដៅយុទ្ធសាស្រ្តសំរាប់លុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា




### ៤.១ យុទ្ធវិធីសំរាប់អនុវត្តកម្មវិធី សំខាន់ៗមានដូចខាងក្រោម:

#### ៤.១.១ សកម្មភាពក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍ (Active HIV case detection) និងធានាឲ្យមានការមកទទួលការថែទាំភ្លាមៗ នៅសេវា Pre-ARTភ្លាមៗ ( immediate enrolment in Pre-ART care)

**"សកម្មក្នុងការស្វែងរកករណីផ្ទុកមេរោគអេដស៍"** គឺរួមមានការផ្តល់ប្រឹក្សា ដើម្បីឲ្យមានការចូលរួមពីដៃគូរួមភេទ (counseling for partner involvement), ការស្វែងរកបណ្តាញដែលពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទ (tracking of

sexual network), វិធីថ្មីៗសំរាប់បង្កើតបណ្តាញសង្គម (innovative social network methods) បន្ថែមលើវិធីបង្កើតបណ្តាញនៃក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ ដែលកំពុងប្រើប្រាស់នៅពេលបច្ចុប្បន្ន។

**៤.១.១.១ ចំពោះក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ និងដៃគូរបស់ពួកគេ** វិធីនិងប្រតិបត្តិការគន្លឹះនឹងមានចែងក្នុងនិយាមនៃបែបបទ សំរាប់អនុវត្តយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការថែទាំព្យាបាលបន្តចំពោះក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ និងការបង្កើតប្រព័ន្ធទំនាក់ទំនងជាមួយសេវាថែទាំសុខភាព)។

- ***ជំរើសយុទ្ធវិធីសំរាប់ធ្វើ*** *modeling:*
  *(ក) ក្រុមប្រជាជនប្រឈមមុខខ្ពស់ នឹងការឆ្លងមេរោគអេដស៍ទាំងអស់ ដែលត្រូវទទួលការធ្វើអន្តរាគមន៍ (ស្ត្រីបំរើតាមសេវាកំសាន្ត, បុរសស្រឡាញ់បុរស, TG, អ្នកចាក់គ្រឿងញៀន /អ្នកប្រើគ្រឿងញៀន, ពិរុទ្ធជន) អ្នកជំងឺរបេង និងអ្នកជំងឺកាមរោគ)*
  *(ខ) ចំណុច(ក) បូកនឹង ដៃគូរួមភេទសំខាន់ៗនៃក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគ អេដស៍ ដែលត្រូវទទួលការធ្វើអន្តរាគមន៍ (ដូចជា សង្សាររបស់ស្ត្រីបំរើតាមសេវាកំសាន្ត, អតិថិជន ជាក់លាក់របស់ស្ត្រីបំរើតាមសេវាកំសាន្ត, ដៃគូរួមភេទរបស់អ្នកចាក់គ្រឿងញៀន បុរសស្រឡាញ់ បុរស , TG និងដៃគូរួមភេទរបស់អ្នកជំងឺកាមរោគ)*

**៤.១.១.២ ចំពោះស្ត្រីមានផ្ទៃពោះ និងដៃគូរួមភេទរបស់គាត់:** វិធី និងប្រតិបត្តិការគន្លឹះ នឹងមានចែងលំអិតក្នុង និយាមនៃបែបបទសំរាប់អនុវត្តយុទ្ធវិធីជំរុញខ្លាំងក្លាការអនុវត្តន៍វិធីសាស្ត្រឆ្លើយតបរួមគ្នារវាងសេវាបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ សេវាសុខភាពបន្តពូជ និងសេវាព្យាបាលជំងឺរបេង ដើម្បីលុបបំបាត់ការ ឆ្លងថ្មីនៃមេរោគអេដស៍ និងជំងឺស្វាយពីកំណើតនៅប្រទេសកម្ពុជា ដែលបានកែលំអនាឆ្នាំ ២០១២។

ការធ្វើតេស្តរហ័សរកមេរោគអេដស៍ (HIV rapid testing) នឹងប្រព្រឹត្តទៅនៅតាមមណ្ឌលសុខភាព ដែលគ្មានសេវា VCCT (Linked Health Centers) ដោយប្រើសំណាកឈាមពីការជួសចុងម្រាមដៃ។ សំណាកឈាមនេះ ប្រើប្រាស់ក្នុងការធ្វើតេស្តដោយប្រើតេស្តរហ័ស (rapid test kits) ដើម្បីរកករណីនៃការឆ្លងមេរោគអេដស៍ និង មេរោគស្វាយ។ គេត្រូវលើកទឹកចិត្តដល់ការធ្វើតេស្តរកមេរោគអេដស៍ក្នុងចំណោមដៃគូរួមភេទរបស់ស្ត្រីមានផ្ទៃពោះ ដែលផ្ទុកមេរោគអេដស៍ តាមរយៈការផ្តល់ប្រឹក្សាស្តីអំពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ស្ត្រីដែល ផ្ទុកមេរោគអេដស៍ទាំងអស់ ដែលមកទទួលសេវា PMTCT ត្រូវបានលើកទឹកចិត្តឲ្យនាំដៃគូរួមភេទ របស់គាត់មក ទទួលការធ្វើតស្តឈាមរកមេរោគអេដស៍។ ប្រសិនបើស្ត្រីមានផ្ទៃពោះ មកទទួលសេវាពិនិត្យសុខភាពមុនពេល សំរាលជាមួយដៃគូរួមភេទរបស់គាត់ អ្នកទាំងពីរនឹងត្រូវផ្តល់ដំបូន្មាន ឲ្យចូលរួមក្នុងវគ្គផ្តល់ប្រឹក្សាសំរាប់ប្តីប្រពន្ធ (couples counseling session)។ ប្រសិនបើតេស្តរកមេរោគស្វាយមានលទ្ធផលវិជ្ជមាន ស្ត្រីត្រូវបញ្ជូនឲ្យទៅ ទទួលការ

ព្យាបាលនៅមន្ទីរពេទ្យបង្អែក ឬនៅគ្លីនីកសុខភាពគ្រួសារ។ ប្តីរបស់គាត់ក៏ត្រូវបញ្ជូនឲ្យទៅទទួលការ ព្យាបាល ហើយកូនរបស់គាត់ដែលមានការប៉ះពាល់ទៅនឹងមេរោគស្វាយ ក៏ត្រូវទទួលការធ្វើតេស្ត និងការព្យាបាល ផងដែរ។

- ***ជំរើសយុទ្ធវិធីសំរាប់ធ្វើ** modeling:*

*(ក) ស្ត្រីមានផ្ទៃពោះទាំងអស់*
*(ខ) ចំណុច(ក) បូកនឹង ដៃគូរួមភេទសំខាន់ៗរបស់ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍*

**៤.១.១.៣ ចំពោះដៃគូរួមភេទរបស់អ្នកផ្ទុកមេរោគអេដស៍ដែលត្រូវបានស្រាវជ្រាវរកឃើញនៅសេវា VCCT និងដែលកំពុងទទួលការថែទាំ pre-ART និង ART** វិធី និងប្រតិបត្តិការគន្លឹះ នឹងមានចែងក្នុងឯកសារគោលគំនិតអំពីការប្រើប្រាស់ការព្យាបាលដោយឱសថ ARV ជាមធ្យាបាយបង្ការការចម្លងមេរោគអេដស៍ (Concept note on ART as Prevention)។

- ***ជំរើសយុទ្ធសាស្ត្រសំរាប់ធ្វើ** modeling:*

*(ក) ដៃគូរួមភេទសំខាន់ៗនៃអ្នកផ្ទុកមេរោគអេដស៍ដែលត្រូវបានស្រាវជ្រាវឃើញនៅសេវា VCCT ដែលមានទីតាំងជាមួយមានសេវា ART ឬដែលកំពុងទទួលការថែទាំ pre-ART និងART*

**៤.១.២ *ការចាប់ផ្តើមភ្លាមៗឬឆាប់រហ័សក្នុងការផ្តល់ការព្យាបាលដោយឱសថ ARV និងការរក្សាឲ្យអ្នកជំងឺបន្តទទួលសេវានេះជាប់ជាប្រចាំ (Immediate/early initiation of ART and retention)***

- យុទ្ធវិធីសំខាន់ៗខាងក្រោមនេះនឹងមានណែនាំលំអិត នៅក្នុងឯកសារគោលគំនិតស្តីអំពីការប្រើប្រាស់ការព្យាបាលដោយឱសថ ARV ជាមធ្យាបាយបង្ការការចម្លងមេរោគអេដស៍:

(ក) ការដាក់ឲ្យមានការធ្វើតេស្តរាប់ចំនួនកោសិកា CD4 នៅតាមសេវាដែលមានទីតាំងជាមួយសេវា *ART* ដើម្បីជួយជំរុញឲ្យឆាប់ទទួលបានសេវា pre-ART ឬ ART។
(ខ) ការពង្រឹង និងតាមដានការផ្តល់សេវា pre-ART និងART ដោយមានការបញ្ចូលនូវការចាប់ផ្តើមភ្លាមៗឬឆាប់រហ័សក្នុងការផ្តល់ការព្យាបាលដោយឱសថ ARV សំរាប់ប្រជាជនគោលដៅ។

***ជំរើសយុទ្ធវិធីសំរាប់ធ្វើ** modeling:*
*(ក) ការអនុវត្តន៍បច្ចុប្បន្នក្នុងការចាប់ផ្តើមព្យាបាលដោយឱសថ ARV គឺនៅកំរិតកោសិកា CD4 តិចជាង ៣៥០ កោសិកា/មម³ (ដោយមិនគិតពីចំនួនកោសិកា CD4 ចំពោះករណីជំងឺរបេង)*
*(ខ) ការចាប់ផ្តើមព្យាបាលដោយឱសថ ARV ដោយមិនគិតពីចំនួនកោសិកា CD4 ចំពោះអ្នកផ្ទុកមេរោគអេដស៍ដែលមានសកម្មភាពផ្លូវភេទ ឬចាក់គ្រឿងញៀន*

*(គ) ចំណុច(ក) បូកនឹង ជំរើស B+នៃការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ចំពោះស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ (ការព្យាបាលដោយឱសថ ARV អស់មួយជីវិត ដោយមិនគិតពីចំនួនកោសិកា CD4 irrespective of CD4 count)*

*(ឃ) ចំណុច (ក)បូកនឹង ជំរើស B+*

៤.១.៣ គោលការណ៍សំរាប់កម្មវិធីរួមមានដូចខាងក្រោម :

- ការប្រើប្រាស់វិធីធ្វើ modeling សំរាប់ណែនាំដល់ការលើកទិសដៅយុទ្ធសាស្ត្រនិងការសំរេចយកជំរើសល្អបំផុត និងការវាយតម្លៃសមិទ្ធផលនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រ
- ការប្រើប្រាស់ពត៌មានជាយុទ្ធសាស្ត្រ (strategic information) សំរាប់ធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពនៃកម្មវិធីអន្តរាគមន៍ និងការស្វែងរក (advocate) ការប្តេជ្ញាចិត្តខាងផ្នែកនយោបាយដើម្បីធានាឲ្យការអនុវត្តន៍កាន់តែមានភាពល្អប្រសើរឡើង និងមាននិរន្តរភាព
- ការប្រើវិធីបែបថ្មីៗ និងការកែតម្រូវការឆ្លើយតបជាប់ជាប្រចាំ ដោយពឹងផ្អែកលើភស្តុតាងច្បាស់លាស់ (based on evidence)
- ការគណនាតម្លៃនៃការធ្វើអន្តរាគមន៍ ដោយផ្អែកលើគោលការណ៍ "អនុវត្តឲ្យបានកាន់តែច្រើនដោយប្រើថវិកាកាន់តែតិច"
- ការរៀបចំឲ្យមានធានានិរន្តរភាពហួសពីកំឡុងពេលនៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍

# ៥. ព័ត៌មានជាយុទ្ធសាស្ត្រ

ដោយផ្អែកលើគោលបំណង, យុទ្ធវិធី, ប្រព័ន្ធ និងសកម្មភាពដែលបានរៀបរាប់ខាងលើគេត្រូវកែលំអនិងពង្រឹងព័ត៌មានជាយុទ្ធសាស្ត្រតាមប្រាំដំណាក់កាលដូចខាងក្រោមនេះ ៖

- ដំណាក់កាលទី១ (២០១២-២០១៣) ប្រតិបត្តិ និងតាមដានវឌ្ឍនភាពនៃការអនុវត្តន៍យុទ្ធវិធីដែលបានស្នើសុំ
- ដំណាក់កាលទី២ (២០១៤-២០១៥) ការពិនិត្យឡើងវិញផ្ទៃក្នុងដោយរួមទាំងការគណនាតាមបែបគំរូគណិតវិទ្យា (Modeling)
- ដំណាក់កាលទី៣ (២០១៦-២០១៩) តាមដានអោយបានខ្លាំងក្លានូវការអនុវត្តន៏យុទ្ធវិធីដែលបានកែលំអដើម្បីឈានឆ្ពោះទៅរកការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍
- ដំណាក់កាលទី៤ (២០២០) ទទួលបាននូវការបញ្ជាក់លទ្ធផលនៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅទូទាំងប្រទេស
- ដំណាក់កាលទី៥ (ចាប់ពីឆ្នាំ២០២១) ធ្វើអោយមាននិរន្តរភាពលើការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍

ដំណាក់កាលទី១ នឹងត្រូវយកចិត្តទុកដាក់លើការតាមដានការអនុវត្តន៍យុទ្ធវិធីដែលបានស្នើសុំដោយសង្កត់ធ្ងន់ទៅលើការវិភាគទិន្នន័យ ការធ្វើការវិភាគបែប Triangulating និងការប្រើប្រាស់ដោយមានប្រសិទ្ធិភាពនូវទិន្នន័យ។ ការធ្វើវិភាគតាមបែប Triangulation នូវទិន្នន័យពីប្រភពដែលមានស្រាប់និងធានាអោយមានការ ប្រើប្រាស់ទិន្នន័យដែលមានស្រាប់និងអនុញ្ញាត្តិអោយមានការយល់ច្បាស់នូវអេពីដេមីសាស្រ្ត (Epidemic) និង តាម ដានវឌ្ឍនភាពឈានទៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍។

## ៥.១. ការអង្កេតតាមដាន និងការសិក្សាស្រាវជ្រាវ

### ៥.១.១. ការអង្កេតតាមដាន

ការលុបបំបាត់ផ្ទះបនក្រោយពីការអនុវត្តន៏ច្បាប់ឆ្នាំ២០០៨ នៃការលុបបំបាត់ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ,របររកស៊ីផ្លូវភេទបានបង្កប់តាមរូបភាពទៅជាគ្រឹះស្ថានកំសាន្តសប្បាយ។ និយមន័យនៃអ្នករកស៊ីផ្លូវភេទក៏បានផ្លាស់ប្តូរដែរ គឺពីស្រ្តីរកស៊ីផ្លូវភេទតាមផ្ទះបនឬដោយផ្ទាល់ទៅជាស្រ្តីបំរើនៅគ្រឹះស្ថានកំសាន្តសប្បាយ (FEW)។ FEW ធ្វើការនៅតាមសួន លក់ស្រាបៀ, ខារ៉ាអូខេ, នៅកន្លែងម៉ាស្សា និងភោជនីយដ្ឋាន។ FEW ទាំងអស់មិនមានកំរិតហានិភ័យដូចគ្នាទេ តាមពិតទៅ FEW មួយចំនួនមិនដែលលក់ភេទទេ។ បញ្ហាដែលសំខាន់នោះគឺអោយនិយមន័យ FEW យ៉ាងដូចម្តេចក្នុងគោលបំណងធ្វើការអង្កេតតាមដានការឆ្លងមេរោគអេដស៍។

បុរសស្រឡាញ់បុរស, អ្នកកែភេទ(TG) និងអ្នកចាក់គ្រឿងញៀនគឺជាក្រុមប្រជាជនគោលដៅដែលប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ ហើយពេលថ្មីៗនេះត្រូវបានបញ្ចូលក្នុងការអង្កេតតាមដានបែបបសកម្ម។ នាពេលកន្លងទៅបុរសស្រឡាញ់បុរសត្រូវបានបញ្ចូលក្នុងការសិក្សាពិសេស។ នៅពេលអនាគតក្រុមនេះនឹងត្រូវបានបញ្ចូលក្នុងការអង្កេតតាមដានជាប្រចាំបែបរួមបញ្ចូលគ្នាទាំងជីវសាស្រ្ត និងការប្រព្រឹត្ត (IBBS)។ ការអង្កេតតាមដានតាមបែបសកម្មត្រូវតែធ្វើអោយប្រសើរឡើងសំរាប់កម្មវិធីជាតិ និងសំដៅលើក្រុមប្រជាជនដែលប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ក្នុងក្រុមខ័ណ្ឌ កម្ពុជា ៣.០ (Cambodia 3.0)។ អត្រាអាំងស៊ីដង់នៃការឆ្លងមេរោគអេដស៍ដែលប្រហាក់ប្រហែល (Proxy incidence) គឺអាចត្រូវគេប៉ាន់ស្មានចេញពីអត្រាប្រេវ៉ាឡង់របស់ក្រុមទាំងនេះ។

IBBS នឹងត្រូវអនុវត្តលើក្រុមប្រជាជនគោលដៅនិមួយៗនៅរៀងរាល់៣ទៅ៤ឆ្នាំ។ ប៉ុន្តែយើងក៏ត្រូវធ្វើការអង្កេតការប្រព្រឹត្ត (BSS) លើក្រុមថ្មីៗប្រឈមមុខនឹងការឆ្លងមេរោគអេដស៍មានជាអាទិ៍ បុគ្គលិក យោធា និងស្រ្តីដែលចំណាកស្រុកទៅរកការងារ និងវ័យជំទង់នៅពេលអនាគតដ៏ឆាប់ៗខាងមុខ។ ទោះជាយ៉ាងណាក៏ដោយកាលវិភាគនៃការអង្កេតតាមដាននឹងត្រូវកែសំរួលដោយក្រុមការងារបច្ចេកទេសអង្កេតតាមដាន ដោយផ្អែកលើតំរូវការទិន្នន័យ និងពេលវេលា ហើយនិងថវិកាដែលមានសំរាប់ធ្វើការងារនេះ។ ឧទាហរណ៍ ការសំរេចចិត្តឈប់ធ្វើការអង្កេតតាមដានអត្រាផ្ទុកមេរោគអេដស៍ (HSS) លើក្រុមស្រ្តីមានផ្ទៃពោះអាចធ្វើទៅបាននៅពេលដែលមានប្រភពទិន្នន័យផ្សេងទៀតមកជំនួស ដើម្បីអោយយើងអាចធ្វើការប៉ាន់ស្មាន និងព្យាករណ៍ណ៍ជាមុននូវចំនួន និងអត្រាផ្ទុកមេរោគនិងអ្នកជំងឺអេដស៍នៅប្រទេសកម្ពុជា។ IBBS លើកក្រោយនឹងគ្រោងធ្វើលើ FEW នៅឆ្នាំ ២០១៤។

ការអង្កេតជំងឺកាមរោគ (SSS) គឺឈជាប្រភេទមួយផ្សេងទៀតនៃ IBBS ដោយសារការធ្វើ SSS តំរូវអោយធ្វើតេស្តកាមរោគមួយចំនួនបន្ថែមទៀតនោះដែលនាំអោយ SSS មានតំលៃខ្ពស់។ ហេតុដូចនេះ យើងគប្បីធ្វើការអង្កេត SSS រៀងរាល់ ៥ ឆ្នាំ ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខខ្ពស់បំផុតនឹងការឆ្លងមេរោគអេដស៍។ បច្ចុប្បន្ននេះការអង្កេត SSS លើ FEW នឹងត្រូវបានបញ្ចប់នៅពេលខាងមុខ។ ចំណែក IBBS ពីរផ្សេងទៀតក្នុងចំណោមអ្នកប្រើគ្រឿងញៀន (PWID/PWUD) និងក្នុងចំណោមអ្នកកែភេទ (TG) គឺកំពុងតែប្រព្រឹត្តទៅ។

ដោយសារតែការអង្កេតតាមដានបែបសកម្មមានតំលៃខ្ពស់ ដូចនេះយើងត្រូវតែស្វែងរកជំរើសដែលមានប្រសិទ្ធិភាពប៉ុន្តែមានតំលៃទាបជាងនេះ តាមរយៈការអង្កេតតាមដានបែបអកម្ម។ ឧទាហរណ៍ ប្រើប្រាស់ទិន្នន័យនៃការបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន (PMTCT) ជំនួសអោយការអង្កេតតាមដានលើក្រុមស្ត្រីមានផ្ទៃពោះមកសេវាពិនិត្យសុខភាពមុនពេលសំរាល (ANC) ។

### ៥.១.២. ការប៉ាន់ស្មានទំហំប្រជាជន

ការប៉ាន់ស្មានទំហំក្រុមប្រជាជនគោលដៅ បាននឹងកំពុងអនុវត្តនៅប្រទេសកម្ពុជាតាំងពីពាក់កណ្តាលទស្សវត្ស២០០០មកម្លេះ។ ទោះបីជាមានការប៉ាន់ស្មានទំហំនៃក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ដូចជា FEW, MSM, TG និង PWID/PWUD ក៏ដោយប៉ុន្តែគុណភាពនៃការប៉ាន់ស្មានទំហំនៃក្រុមប្រជាជនគោលដៅទាំងនោះ មិនស្របទៅនឹងចំនួនដែលមាននោះទេ។ ម៉្យាងទៀតបច្ចុប្បន្ននេះការប៉ាន់ស្មានទំហំក្រុមប្រជាជនគោលដៅខ្លះបានហួសសម័យទៅហើយ។

ការប៉ាន់ស្មានទំហំក្រុមគោលដៅមួយចំនួនត្រូវធ្វើឡើងដោយរួមបញ្ចូលជាមួយ IBBS ដូចជាករណី PWID/PWUD និងTG ដែលការប៉ាន់ស្មានទំហំកំពុងតែប្រព្រឹត្តទៅ។ ការរួមបញ្ចូលការអង្កេតតាមដាន និងប៉ាន់ស្មានទំហំក្រុមប្រជាជនគោលដៅគឺជាការអនុវត្តន៏ល្អបំផុត ដែលអាចជួយកាត់បន្ថយតំលៃក្នុងការប្រមូលទិន្នន័យពីការអង្កេតរៀងរាល់ ៣ ទៅ ៤ ឆ្នាំនឹងត្រូវបង្គ្រប់និងវិភាគបែប Triangulation ជាមួយនឹងទិន្នន័យប្រមូលបានតាមរយៈធ្វើផែនទី (mapping) នៃក្រុមប្រជាជនគោលដៅ។

ជាទូទៅ យើងត្រូវតែប្រឹងប្រែងបន្ថែមទៀតនាពេលអនាគត ដើម្បីធ្វើអោយល្អប្រសើរឡើងនូវការប៉ាន់ស្មានទំហំក្រុមប្រជាជនគោលដៅ ជាពិសេសវិធីសាស្ត្រដែលប្រើក៏ដូចជាការសំរបសំរួលនូវសកម្មភាពជាមួយស្ថាប័ននិងដៃគូអភិវឌ្ឍន៏នានា។

ការប៉ាន់ស្មាននេះមានសារៈសំខាន់ណាស់ ជាពិសេសសំរាប់ប្រើប្រាស់ជាភាគបែងដែល ត្រូវការក្នុងការគណនាការគ្របដណ្តប់នៃអន្តរាគមន៏ផ្សេងៗ។

### ៥.១.៣. ការសិក្សាពិសេស និងការសិក្សាស្រាវជ្រាវម្តងម្កាល

ក្នុងពេលកន្លងមកដៃគូពាក់ព័ន្ធជាច្រើន រួមមានភ្នាក់ងាររដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៏, អង្គការមិនមែនរដ្ឋាភិបាល, វិទ្យាស្ថានសិក្សាស្រាវជ្រាវបានធ្វើការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ជាច្រើននៅប្រទេសកម្ពុជា។ ដើម្បីសំរបសំរួលការសិក្សាទាំងអស់នេះ និងធ្វើអោយល្អប្រសើរដល់ការប្រើប្រាស់ទិន្នន័យសំរាប់កែលំអការអនុវត្តន៏សកម្មភាពនៃអន្តរាគមន៏ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានរៀបចំរបៀបវារៈនៃការស្រាវជ្រាវពាក់ព័ន្ធនឹងមេរោគអេដស៍ នៅក្នុងឆ្នាំ២០០៧។ របៀបវារៈនេះនឹងត្រូវធ្វើបច្ចុប្បន្នភាព ហើយសកម្មភាពនឹងត្រូវពង្រឹងផ្អែកលើយុទ្ធវិធីដែលមានចែងក្នុងក្របខ័ណ្ឌនៃគោលគំនិតកម្ពុជា ៣.០នេះ (Conceptual Framework of Cambodia 3.0) និងផលិតបាននូវទិន្នន័យពិសេសសំរាប់ប្រទេសកម្ពុជាដែលអាចយកទៅប្រើក្នុងគំរូ Mathematic (Mathematical Modeling)។

## ៥.២. របាយការណ៍នៃករណីឆ្លងមេរោគអេដស៍

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានប្រព័ន្ធរបាយការណ៍នៃករណីឆ្លងថ្មីនៃមេរោគអេដស៍ប៉ុន្តែមានតែរបាយការណ៍សរុបចំនួន ដែលបានធ្វើរោគវិនិច្ឆ័យនៅមណ្ឌលផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ហើយការវិភាគទិន្នន័យដែលបានពីរបាយការណ៍សរុបនេះគឺនៅមានកំរិត ហើយក៏មិនអាចញែកចេញនូវអតិថិជនដែលបានធ្វើតេស្តរកមេរោគអេដស៍ច្រើនដងបានទេ។

ដើម្បីឈានទៅបង្កើតប្រព័ន្ធរបាយការណ៍នៃករណីឆ្លងថ្មី នៃមេរោគអេដស៍ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសំរាប់គ្រប់អតិថិជនដែលទើបនឹងបានធ្វើរោគវិនិច្ឆ័យថាបានឆ្លងមេរោគអេដស៍នោះគឺ ត្រូវតែប្រមូលព័ត៌មានពីទំរង់ចុះបញ្ជីផ្តល់ប្រឹក្សា (ទំរង់រាយការណ៍នៃករណីឆ្លងមេរោគអេដស៍) ដោយមានឈ្មោះ និងអត្តសញ្ញាណផ្សេងៗ ហើយត្រូវបញ្ចូលករណីឆ្លងថ្មីនៃមេរោគអេដស៍នេះ ទៅក្នុងទិន្នន័យអេឡិចត្រូនិចរបស់មណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ដើម្បីសរុបនិងធ្វើការវិភាគ។ ប្រព័ន្ធរបាយការណ៍នៃករណីឆ្លងថ្មីនេះនឹងអាចកាត់បន្ថយឬលុបបំបាត់ការរាប់អតិថិជន ដែលធ្វើតេស្តវិជ្ជមានច្រើនដង ដែលមានប្រយោជន៍ដល់ការតាមដានករណីឆ្លងថ្មីនៅសេវាមុនផ្តល់ឱសថប្រឆាំងនឹងមេរោគអេដស៍ (Pre ART) ។ ទន្ទឹមនឹងនេះរបាយការណ៍នៃករណីឆ្លងថ្មីនេះក៏ផ្តល់នូវព័ត៌មានថ្មីៗ អំពីបុគ្គលដែលឆ្លងថ្មីនៃមេរោគអេដស៍ដូចជារបៀបនៃការចំលងមេរោគអេដស៍ (FEW, MSM, TG, PWID, ដៃគូនៃអ្នកផ្ទុកមេរោគអេដស៍) អាយុ, ភេទ និងទីតាំង។ ប្រព័ន្ធរបាយ-ការណ៍នៃករណីឆ្លងមេរោគអេដស៍ មានលក្ខណៈបុគ្គលត្រូវបានរៀបចំដែលនឹងជួយដល់ការតាមដានវឌ្ឍនភាពនៃយុទ្ធវិធីក្នុងការស្វែងរកយ៉ាងសកម្មករណីឆ្លងថ្មីនិងបញ្ចូលភ្លាមៗទៅក្នុងសេវាថែទាំ និង ព្យាបាល។

យើងក៏ត្រូវប្រឹងប្រែងយកចិត្តទុកដាក់ដល់គុណភាព និងភាពពេញលេញនៃរបាយការណ៍ផងដែរ។ ការប្រើប្រាស់ទិន្នន័យនៃរបាយការណ៍ជាប្រចាំត្រូវពឹងផ្អែកទាំងស្រុង លើភាពពេញលេញ និងភាពសុក្រិតនៃប្រព័ន្ធរបាយការណ៍នៃករណីនៅសេវាថែទាំព្យាបាលបន្ត។

របាយការណ៍នៃករណីឆ្លងមេរោគអេដស៍និងព្រឹត្តការណ៍ដែលកើតមានឡើងក្នុងកំឡុងពេលថែទាំព្យាបាលដូចជាកំរិតCD4លើកដំបូង, រោគវិនិច្ឆ័យករណីជំងឺអេស៍ និងស្លាប់។ នៅសេវាថែទាំព្យាបាលបន្ត អ្នកជំងឺអេដស៍ដែលបានអនុវត្តការពង្រឹងគុណភាពបន្ត (Continuous quality improvement) គឺគេបានតាមដាននូវព្រឹត្តការណ៍កើតមានក្នុងកំឡុងពេលថែទាំព្យាបាលនៅរៀងរាល់ត្រីមាស តាមរយៈការវិភាគទិន្នន័យ នៃសេវាមុនការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ (Pre-ART) ហើយគេក៏អាចវិភាគទិន្នន័យសរុបថ្នាក់ជាតិផងដែរ។ កំរិតមធ្យម CD4 នៅពេលចាប់ផ្តើមទទួលសេវាមុនការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍បានកើនឡើងពីឆ្នាំ ២០០៧ មក ២០១០ បង្ហាញថាអ្នកជំងឺចូលមកទទួលការព្យាបាលឆាប់ជាងមុន។ ការវិភាគ និងផ្តល់ព័ត៌មានត្រឡប់ពីព្រឹត្តការណ៍កើតមាន ក្នុងកំឡុងពេលព្យាបាលដល់កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍-ជំងឺកាមរោគខេត្ត-រាជធានី និងសេវាCoC នឹងជួយដល់ការតាមដានវឌ្ឍនភាពនៃការអនុវត្តន៍យុទ្ធសាស្រ្តគន្លឹះ ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍។

## ៥.៣. ការតាមដានកម្មវិធីជាប្រចាំសំរាប់យុទ្ធវិធីនិមួយៗ

ទិន្នន័យដែលប្រមូលបានពីកម្មវិធីជាប្រចាំដូចជា CoPCT, PMTCT, VCCT, STI, Pre ART/ART នឹងមានសារៈសំខាន់សំរាប់កត់សំគាល់អ្នកប្រើប្រាស់សេវា តើញឹកញាប់ប៉ុណ្ណា ឬព្រមទាំងបញ្ជាក់ច្បាស់ថាក្រុមគោល

ដៅបានទទួលសេវាទាំងអស់នោះឬទេ។ ប្រព័ន្ធ និងគំរោងតាមដានកម្មវិធីជាប្រចាំត្រូវបានកែលំអតាមរយៈការជំរុញខ្លាំងក្លាការអនុវត្តន៏វិធីសាស្រ្តឆ្លើយតបរួមគ្នា និងនិយាមនៃបែបបទសំរាប់អនុវត្តការឆ្លើយតបគ្រប់ជ្រុងជ្រោយ ការបង្ការ និងថែទាំព្យាបាលដើម្បីធានាភាពសុខដមនីយកម្មនិងតំរែតំរឹមក្នុងការប្រឹងប្រែងតាមដាននិងរាយការណ៍របស់ប្រតិបត្តិករនិងអ្នកផ្តល់សេវា។ គេត្រូវប្រើសូចនករករណីរួមមួយឈុតដែលមាននិយមន័យ, ឧបករណ៍តាមដាន និងរបាយការណ៍ប្រហាក់ប្រហែលគ្នា ដែលនាំអោយមានការងាយស្រួលក្នុងការសរុប និងវិភាគ ការប្រើប្រាស់សេវានិងការគ្របដណ្តប់ការអនុវត្តន៏កម្មវិធីនៃអន្តរាគមន៏។

ការតាមដានទិន្នន័យជាប្រចាំតំរូវអោយមានការពិនិត្យយ៉ាងទៀងទាត់, ធ្វើការវិភាគ និងបកស្រាយដោយអ្នកផ្តល់សេវា ហើយអ្នកធ្វើការសំរេចត្រូវតាមដានវឌ្ឍនភាព និងកែលំអការអនុវត្តន៏កម្មវិធីនៃអន្តរាគមន៏។ ការតាមដានទិន្នន័យជាប្រចាំក៏នឹងតំរូវអោយធ្វើការវិភាគបែប Triangulation ជាមួយទិន្នន័យដែលបានពីប្រភពផ្សេងៗ (ឧទាហរណ៍ បានពីការអង្កេតតាមដាន, ការស្រាវជ្រាវបែបប្រតិបត្តិ, ការវាយតំលៃ-ល-)។ មិនមានប្រភពទិន្នន័យណាមួយល្អឥតខ្ចោះទេ ហេតុនេះការវិភាគទិន្នន័យបែបTriangulationនឹងជួយដល់ការយល់ដឹងពីចំណុចខ្លាំង និងចំណុចខ្សោយនៃប្រភពទិន្នន័យនិមួយៗនិងជួយដល់ការបកស្រាយទិន្នន័យ។ ការធ្វើវិភាគបែប Triangulationត្រូវតែធ្វើអោយបានទៀងទាត់ក្នុងគោលបំណងពង្រឹងសមត្ថភាពនៃការវិភាគ និងបកស្រាយទិន្នន័យព្រមទាំងប្រើប្រាស់ទិន្នន័យអោយមានប្រយោជន៏ក្នុងការធ្វើអោយប្រសើរឡើងនូវការអនុវត្តន៏កម្មវិធីនៃអន្តរាគមន៏។

សូចនាករនៃផលសំរេច (Impact) និងលទ្ធផល(Output)ជាប្រចាំ ហើយនិងគោលដៅបានបង្កើតឡើងដើម្បីលុបបំបាត់ការឆ្លងមេរោគអេដស៏ ពីម្តាយទៅកូននៅក្នុងនិយាមបែបបទនៃយុទ្ធវិធីជំរុញខ្លាំងក្លាការឆ្លើយតបរួមគ្នា។ ទិន្នន័យសំរាប់សូចនាការលទ្ធផលជាប្រចាំសំរាប់សេវាបង្ការការចំលងមេរោគអេដស៏ ពីម្តាយទៅកូនត្រូវបានប្រមូលទូទៅជារៀងរាល់ត្រីមាស ហើយវឌ្ឍនភាពឈានទៅដល់គោលដៅ ត្រូវបានពិនិត្យឡើងវិញជាទៀងទាត់យ៉ាងតិចពីរដងក្នុងមួយឆ្នាំ។ ការធ្វើគំរូផលសំរេចសំរាប់ការលុបបំបាត់ការចំលងមេរោគអេដស៏ ពីម្តាយទៅកូនអាចធ្វើទៅបានដោយប្រើប្រាស់កញ្ចប់គំរូ និងឧបករណ៍មួយចំនួនធំ ដោយផ្អែកទៅលើទិន្នន័យគ្របដណ្តប់កម្មវិធីជាប្រចាំពីសូចនាករទិន្នផលទៅជាផលដែលដាក់បញ្ចូល (Input)។ វឌ្ឍនភាពនៃការឈានទៅទទួលបាននូវសូចនាករផលសំរេចដែលមានគោលដៅលុបបំបាត់ការចំលងមេរោគអេដស៏ពីម្តាយទៅកូន ត្រូវវាយតំលៃជាទៀងទាត់រៀងរាល់ឆ្នាំដោយប្រើប្រាស់ឧបករណ៍ដែលបានបង្កើតឡើងដោយដៃគូ។ ក្នុងកំឡុងពេលធ្វើលំហាត់ប្រចាំឆ្នាំ កម្មវិធីត្រូវផលិតតារាង Input ដែលនឹងអាចប្រាប់ពីលំហាត់គ្រប់ជ្រុងជ្រោយនៃការធ្វើគំរូនៅថ្ងៃខាងមុខដោយប្រើប្រាស់ Spectrum ។ គំរូនៃការចំលងមេរោគអេដស៏ពីម្តាយទៅកូននឹងត្រូវបានរួមបញ្ចូលទៅក្នុងការប៉ាន់ស្មានប្រេវ៉ាឡង់មេរោគអេដស៏នៅពេលក្រោយដោយប្រើប្រាស់ Spectrum (យោងទៅលើផ្អែកទី៤)។

កិច្ចប្រឹងប្រែងក្នុងការពង្រឹងប្រព័ន្ធតាមដានជាប្រចាំ នឹង ត្រូវបង្គ្រប់ដោយការផ្តើមគំនិតប្រព័ន្ធឯកអត្តសញ្ញាណដែលអនុញ្ញាត្តិអោយវាយតំលៃការប្រើប្រាស់សេវា និង តាមដានអតិថិជននៅតាមសេវាផ្សេងៗ។ វឌ្ឍនភាពក៏ត្រូវបានពង្រឹងតាមរយៈការធ្វើអោយល្អប្រសើរនូវការប៉ាន់ប្រមាណចំនួនប្រជាជន ដែលបច្ចុប្បន្ននេះបាននិងកំពុងអនុវត្តតាមបែប IBBS ក្នុងនោះការប៉ាន់ប្រមាណទំហំចំនួនប្រជាជននៃក្រុមអ្នកប្រើគ្រឿងញៀន, ក្រុមចាក់គ្រឿងញៀន និងក្រុមកែភេទបាននឹងកំពុងតែប្រព្រឹត្តទៅ។

## ៥.៤. ការធ្វើគំរូបែបគណិតវិទ្យា

ការប៉ាន់ស្មាន និងការព្យាករណ៍ណ៍ជាមុននូវទិន្នន័យនៃការឆ្លងមេរោគអេដស៍ និងតំរូវការសេវាបង្ការ ថែទាំព្យាបាលជំងឺអេដស៍ត្រូវបានរៀបចំនិងចងក្រងនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៨។ ទិន្នន័យទាំងអស់នោះត្រូវបានឯកភាពដោយសិក្ខាសាលាព្រមព្រៀងគ្នាជាឯកឆន្ទ (Consensus Workshop) ដែលចូលរួមដោយអ្នកជំនាញជាតិ និងអន្តរជាតិ។ ព័ត៌មានជាយុទ្ធសាស្ត្រដែលបានបង្កើតឡើងតាំងពីដើមដល់ពេលនេះ មានសារៈសំខាន់ក្នុងការយល់ដឹងពីនិន្នាការនៃការឆ្លងមេរោគអេដស៍ និងវាយតំលៃផលសំរេចនៃការឆ្លើយតបថ្នាក់ជាតិ។ បច្ចេកទេសក្នុងការប្រើប្រាស់គំរូបែបគណិតវិទ្យាមានការរីកចំរើន ហើយទិន្នន័យដែលប្រើប្រាស់ក្នុងគំរូនេះក៏មានការល្អប្រសើរជាងមុន ដែលនាំអោយលទ្ធផលនៃការប៉ាន់ស្មាន និងការព្យាករណ៍ណ៍បានល្អប្រសើរជាងមុន។ ការប៉ាន់ស្មាន និងការព្យាករណ៍ថ្មីត្រូវបានអនុវត្តនៅរៀងរាល់៥ឆ្នាំដែលនឹងផ្តល់ព័ត៌មានពីប្រវ៉ាឡង់នៃការឆ្លងមេរោគអេស៍, ការឆ្លងថ្មីនៃមេរោគអេដស៍, ការស្លាប់ដែលពាក់ព័ន្ធនឹងជំងឺអេដស៍, កុមារកំព្រា, តំរូវការការព្យាបាល។ល។

ការវាស់វែងអត្រាអាំងស៊ីដង់មានសារៈសំខាន់ណាស់ គឺអនុញ្ញាត្តិអោយមានការតាមដាននិន្នាការនៃការឆ្លងមេរោគអេដស៍បានប្រសើរជាងមុន, កំណត់ទិសដៅអន្តរាគមន៍បង្ការ, កំណត់អាទិភាពនៃការឆ្លើយតបដែលត្រូវរកធនធាន ដើម្បីកាត់បន្ថយជាអតិបរមានូវចំនួននៃការឆ្លងថ្មីនៃមេរោគអេដស៍ និងអនុញ្ញាត្តិអោយធ្វើការវាយតំលៃនូវផលសំរេចនៃកម្មវិធីបង្ការ។ មានវិធីសាស្ត្រនៃការវាស់វែងដោយផ្ទាល់ និងតេស្តមន្ទីរពិសោធន៍។

ដោយសារតែតំរូវការសំណាកឈាមយ៉ាងច្រើន ដើម្បីធ្វើតេស្តនៅមន្ទីរពិសោធន៍ (ឧទាហរណ៍៖ តេស្ត BED) ជាប្រចាំហើយដែលមានតំលៃខ្ពស់ក្នុងការវាស់អាំងស៊ីដង់ដោយផ្ទាល់តាមរយៈការសិក្សាស្រាវជ្រាវតាមបែបតាមដាន (Longitudinal cohort study) ប្រទេសកម្ពុជាមានផែនការនឹងបន្តប្រើប្រាស់វិធីសាស្ត្រមិនផ្ទាល់ដូចជាការប្រើប្រាស់គំរូបែបគណិតវិទ្យា និងអាំងស៊ីដង់ប្រហាក់ប្រហែល (Proxy incidence) ដោយប្រើប្រវ៉ាឡង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមក្រុមគោលដៅ។ ពង្រឹងប្រព័ន្ធរបាយការណ៍ករណីឆ្លងមេរោគអេដស៍ គឺរួមចំណែកដល់ការវិភាគបែប Triangulation នូវទិន្នន័យសំរាប់ប៉ាន់ស្មានអត្រាអាំងស៊ីដង់នៃការឆ្លងមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនផ្សេងៗ។

ដើម្បីរៀបចំការអនុវត្តន៍ដំណាក់កាលទី២ និងបន្តទៅមុខឆ្ពោះទៅលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍គឺត្រូវធ្វើអោយល្អប្រសើរឡើងនូវវិធីសាស្ត្រ ដែលអាចអោយស្រាវជ្រាវរកឃើញព័ត៌មានសំរាប់ប៉ាន់ស្មានអាំងស៊ីដង់មេរោគអេដស៍។

ការប្រើប្រាស់គំរូបែបគណិតវិទ្យាអាចឆ្លើយនឹងសំនួរដូចខាងក្រោម៖

- តើការរួមផ្សំអន្តរាគមន៍ដ៏សមស្របណាដែលអាចទទួលបានផលច្រើនជាងគេ ដោយអស់តំលៃតិចបំផុត។
- តើទំហំនៃផលចំណេញពីការបង្ការដោយចាប់ផ្តើមភ្លាមៗ នូវការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ក្នុងចំណោមក្រុមប្រជាជនគោលដៅដូចជា FEW, បុរសស្រឡាញ់បុរស, TG និងអ្នកចាក់គ្រឿងញៀនមានប៉ុណ្ណា?
- នៅស្ថានភាពណាដែលការព្យាបាលភ្លាម ដោយឱសថប្រឆាំងនឹងមេរោគអេដស៍ អាចចាប់ផ្តើមដើម្បីទទួលបានផលយ៉ាងច្រើនទៅលើការឆ្លងរាលដាលនៃមេរោគអេដស៍។

- តើលទ្ធផលនៃការព្យាបាលដោយឱសថ ARV ជាមធ្យោបាយដើម្បីបង្ការការចំលង មេរោគអេដស៍អាច បង្កើននូវប្រសិទ្ធិភាពនៃការឆ្លើយតបហើយត្រូវការតំលៃបន្ថែមប៉ុណ្ណា?

### ៥.៥. ការធ្វើផែនការ និងការវាយតំលៃ

ទិន្នន័យបែបបរិមាណ និងបែបគុណភាពនឹងត្រូវប្រមូលនៅតាមទីកន្លែងសាកល្បងមួយចំនួនដើម្បីរៀបចំ ទិន្នន័យជាមូលដ្ឋានសំរាប់ការវាយតំលៃនៅពេលក្រោយ (នៅពាក់កណ្តាលគំរោង និងនៅចុងបញ្ចប់គំរោង)។ ទិន្នន័យជាមូលដ្ឋាននឹងត្រូវប្រមូលនៅពេលចាប់ផ្តើមអនុវត្តកម្មវិធីនៃអន្តរាគមន៍យកពីកំណត់ត្រា និងប្រភពផ្សេងៗ នៅតាមសេវានានា។ ការវាយតំលៃនឹងត្រូវធ្វើទាំងវិធីបរិមាណ និងគុណភាពហើយគ្របដណ្តប់ទាំងសេវានៃអង្គការ មិនមែនរដ្ឋាភិបាល និងសាធារណៈដែលតាំងនៅតំបន់សាកល្បង។

ការវាយតំលៃជាក់លាក់នឹងពិនិត្យឡើងវិញជាច្រើនទៀត គឺត្រូវរៀបចំ និងត្រៀមអនុវត្ត ដើម្បីវាយតំលៃលើ សកម្មភាពសមស្រប, ប្រសិទ្ធិភាព, តំលៃ និងនិរន្តភាពនៃអន្តរាគមន៍លើចំណុចគោលដៅ។ គុណភាពនៃសេវាក៏នឹង ត្រូវវាយតំលៃរួមទាំងការស្រាវជ្រាវតាមបែបការពេញចិត្តរបស់អតិថិជន។ ពេលវេលាសំរាប់ការវាយតំលៃនឹងត្រូវ កំណត់ផ្អែកលើតាមតំរូវការទិន្នន័យ ហើយការងារនេះត្រូវពាក់ព័ន្ធនឹងការវាយតំលៃឯករាជ្យឬការពិនិត្យឡើងវិញផ្ទៃ ក្នុងផ្អែកលើព័ត៌មានបែបណាដែលត្រូវការដើម្បីកែលំអយុទ្ធវិធី, កញ្ចប់សេវាសកម្មភាព, កត់ត្រាឯកសារ, លទ្ធផល នៃការសាកល្បង និងផលសំរេច។

## ៦. សម្មតិកម្មទាក់ទងនឹងការអនុវត្តន៍កម្មវិធី (Programmatic assumptions)

៦.១ មានការរក្សានិរន្តរភាពនៃការគ្របដណ្តប់ខ្ពស់នៃសេវាសុខភាពសំរាប់ថែទាំជំងឺអេដស៍

៦.២ មានការរក្សានិរន្តរភាពនៃការគ្របដណ្តប់ខ្ពស់នៃសេវាបង្ការ សំរាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់ នឹងការឆ្លងមេរោគអេដស៍

៦.៣ មានការបង្កបរិយាកាសគាំទ្រដល់ការអនុវត្តន៍ (Enabling environment will be conducive)

៦.៤ មានលទ្ធភាពក្នុងការគៀងគថវិកា(ជាតិ និងអន្តរជាតិ)សំរាប់គាំទ្រដល់ការអនុវត្តន៍យុទ្ធវិធី (Predictability of resources (domestic and international)

## ៧ ការគ្រប់គ្រងកម្មវិធី

ដើម្បីគ្រប់គ្រងកម្មវិធីក្រុមការងារមួយចំនួន ដូចខាងក្រោមនឹងត្រូវបង្កើតឡើង៖

### ៧.១ ក្រុមស្នូលនៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍

- បង្កើត និងកែលម្អទិសដៅជាយុទ្ធសាស្ត្រ និងផែនការតាមដាន និងវាយតំលៃ
- ណែនាំអនុក្រុម និងតាមដានវឌ្ឍនៈភាពរបស់ពួកគេ
- ណែនាំ និងសំរបសំរួលការបង្កើត វិធីសាស្ត្រថ្មី និងពាក់ព័ន្ធច្រើនផ្នែក (cross cut) (ឧទាហរណ៍ តាម ដានដៃគូ និងការជាប់ទាក់ទងរបស់ពួកគេ ណែនាំធ្វើតេស្ត CD4 នៅទីតាំងមណ្ឌលធ្វើតេស្តរកមេរោគអេ ដស៍ ដោយស្ម័គ្រ ចិត្ត និងរក្សាការសំងាត់។)

- ណែនាំការពិនិត្យឡើងវិញ និងកែលម្អការអនុវត្តន៍កម្មវិធី (ឧទាហរណ៍ ការរកឃើញករណីអោយបានឆាប់ នៅតាមក្រុមប្រជាជនគោលដៅផ្សេងៗ ហើយផ្តល់ភ្លាមៗ ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍) និងធ្វើ Modeling
- ចងក្រងឯកសារអំពីដំណើរការ និងលទ្ធផលនៃការផ្តួចផ្តើមគំនិត ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា
- អនុវត្តការស្វែងរកការគាំទ្រ និងប្រភពធនធាន

## ៧.២ អនុក្រុមនៃយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថែទាំ ព្យាបាលបន្ត ចំពោះក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (Boosted CoPCT)

- បង្កើតនិយាមបែបបទនៃ Boosted CoPCT រួមទាំងការបង្កើតវិធីសាស្រ្តថ្មីៗ (ឧទាហរណ៍ ការតាមដាន និងការជាប់ទាក់ទង របស់ដៃគូចំបង របស់ក្រុមប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍)
- អនុវត្តនិយាមនៃបែបបទ រួមទាំងការបណ្តុះបណ្តាល និងកែលំអឧបករណ៍តាមដាន។ល។
- តាមដានការអនុវត្តន៍និយាមនៃបែបបទ និងផ្តល់ជាគំនិតពេលការពិនិត្យឡើងវិញ និងការធ្វើ modeling

## ៧.៣ អនុក្រុមនៃយុទ្ធវិធីជំរុញខ្លាំងក្លាការឆ្លើយតបរួមគ្នា រវាងសេវាថែទាំព្យាបាលជំងឺអេដស៍ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងជំងឺរបេង ដើម្បីការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ លើកុមារ និងជំងឺស្វាយ ពីកំណើត នៅប្រទេសកម្ពុជា

- បង្កើតនិយាមបែបបទសំរាប់អនុវត្តយុទ្ធវិធីជំរុញខ្លាំងក្លានៃការឆ្លើយតបរួមគ្នា រវាងសេវាថែទាំព្យាបាលជំងឺអេដស៍ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងជំងឺរបេង ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍លើកុមារ និងការ ឆ្លងជំងឺស្វាយពីកំណើត នៅប្រទេសកម្ពុជា រួមទាំងការបង្កើតយុទ្ធវិធីថ្មីៗ (ឧទាហរណ៍ ការតាមដាន និងការពាក់ព័ន្ធរបស់ដៃគូស្ត្រីមានផ្ទៃពោះ ដែលផ្ទុកមេរោគអេដស៍)
- អនុវត្តនិយាមនៃបែបបទ រួមទាំងការបណ្តុះបណ្តាល និងកែសំរួលឧបករណ៍តាមដាន។ល។
- តាមដានការអនុវត្តន៍និយាមនៃបែបបទ និងផ្តល់ជាគំនិត ពេលពិនិត្យឡើងវិញ និងការធ្វើ modeling

## ៧.៤ អនុក្រុមនៃការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ជាមធ្យោបាយដើម្បីបង្ការការចំលងមេរោគអេដស៍

- បង្កើតឯកសារគោលគំនិត នៃការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ជាមធ្យោបាយដើម្បីបង្ការការចំលងមេរោគអេដស៍ រួមទាំងការ បង្កើតយុទ្ធវិធីថ្មីៗ (ឧទាហរណ៍: ការតាមដាន និងការពាក់ព័ន្ធរបស់ដៃគូអ្នកផ្ទុកមេរោគអេដស៍, ការណែនាំធ្វើតេស្ត CD4 នៅមណ្ឌលធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់) និងការវាយតំលៃ ពីភាពដែល អាចធ្វើបាន។
- ស្នើសុំក្រសួងសុខាភិបាល ដើម្បីអនុម័តអោយចាប់ផ្តើមអនុវត្តជាផ្លូវការ
- អនុវត្តឯកសារគោលគំនិត រួមទាំងការបណ្តុះបណ្តាល និងកែសំរួលនូវឧបករណ៍តាមដាន។ល។
- តាមដានការអនុវត្តន៍នូវឯកសារគោលគំនិត និងផ្តល់ជាគំនិតក្នុងការពិនិត្យឡើងវិញនូវការធ្វើ modeling

### ៧.៥ អនុក្រុមនៃព័ត៌មានជាយុទ្ធសាស្ត្រ

- បង្កើតគំរោងគោលគំនិត សំរាប់ការធ្វើ modeling និងរៀបចំការប្រជុំពិគ្រោះយោបល់
- ប្រមូលគំនិត សំរាប់ធ្វើ modeling និងចាប់ផ្តើមការងារនេះ
- ពិគ្រោះ និងផ្សព្វផ្សាយ លទ្ធផលនៃការធ្វើ modeling
- រៀបចំបង្កើតពិធីសារនៃការស្រាវជ្រាវបែបប្រតិបត្តិ ដើម្បីប្រមូល អញ្ញាតិបន្ថែមទៀត សំរាប់ធ្វើ modeling
- រៀបចំធ្វើការស្រាវជ្រាវបែបប្រតិបត្តិ និងផ្សព្វផ្សាយនូវរបកគំឃើញ
- អនុវត្តការពិនិត្យឡើងវិញនៃការធ្វើ modeling និងការសិក្សាស្រាវជ្រាវបែបប្រតិបត្តិ
- ពិនិត្យឡើងវិញ និងពង្រឹងប្រព័ន្ធការអង្កេតតាមដាន និងតាមដានកម្មវិធី

<u>សមាជិកភាពនៃក្រុមស្នូលនៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍</u>

- ប្រធាន: នាយកមជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺអេដស៍ សើស្បែក និងកាមរោគ (វេជ្ជ មាន ឈី វុន)
- អ្នកសំរបសំរួល: អនុប្រធានការិយាល័យបច្ចេកទេស មជ្ឈមណ្ឌលជាតិ (វេជ្ជ សេង សុភាព)
- មន្រ្តីបង្គោលនៃអនុក្រុមនៃយុទ្ធវិធីជំរុញខ្លាំងក្លា ការបង្ការ ថែទាំ ព្យាបាលបន្ត ដល់ក្រុមប្រជាជនប្រឈមមុខខ្ពស់ (វេជ្ជ នេត្ត សានសុទ្ធី)
- មន្រ្តីបង្គោលនៃអនុក្រុមជំរុញខ្លាំងក្លាការឆ្លើយតបរួមគ្នា (វេជ្ជ សំរិត សុវណ្ណរិទ្ធិ)
- មន្រ្តីបង្គោលនៃអនុក្រុមការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ជាមធ្យោបាយដើម្បីបង្ការការចំលងមេរោគអេដស៍ (វេជ្ជ ង៉ូវ បូរ៉ា)
- មន្រ្តីបង្គោលនៃអនុក្រុមការធ្វើគំរូ និងការស្រាវជ្រាវបែបប្រតិបត្តិ (វេជ្ជ ឈា ឆវណ្ណ) និងសាស្ត្រចារ្យ សាធុន វឌ្ឍនះ
- អនុប្រធានផ្នែកស្រាវជ្រាវ នៃមជ្ឈមណ្ឌលជាតិ (វេជ្ជ ខោន វោហិទ្ធ)
- អនុប្រធាន NCHADS និងជាប្រធានផ្នែកគ្រប់គ្រងទិន្នន័យ នៃមជ្ឈមណ្ឌលជាតិ (លោក ម៉ម សុវត្ថា)
- អង្គការដៃគូអភិវឌ្ឍន៍ (WHO, UNAIDS, UNICEF, US-CDC,USAID, CHAI, FHI 360...)
- តំណាងសហគមន៍ (PLHIV, EWs, MSM, DU/IDU,.....)

## ៨. ផែនទីបង្ហាញផ្លូវ

- ក្របខ័ណ្ឌនៃគោលគំនិត ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា នៅឆ្នាំ ២០២០, និយាមនៃបែបបទនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ និងការផ្តល់ប្រឹក្សា, និយាមនៃបែបបទ សំរាប់អនុវត្តយុទ្ធវិធីជំរុញខ្លាំងក្លាការឆ្លើយតបរួមគ្នា រវាងសេវាថែទាំព្យាបាលជំងឺអេដស៍, សុខភាពផ្លូវភេទ, និងសុខភាពបន្តពូជ និងជំងឺរបេង ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ លើទារក-កុមារ និងការឆ្លងជំងឺស្វាយពីកំណើត នៅប្រទេសកម្ពុជា, និយាមនៃបែបបទនៃយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថែទាំ និងព្យាបាលបន្ត ចំពោះក្រុម ប្រជាជនប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍, គោលគំនិតនៃការប្រើប្រាស់ការព្យាបាលដោយ ARV ជាមធ្យោបាយ ដើម្បីបង្ការការចំលងមេរោគអេដស៍ ដែលជាផ្នែកមួយនៃលុប បំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា។

| ឯកសារ | កាលបរិច្ឆេទ ជាគោលដៅ |
|---|---|
| ក្របខ័ណ្ឌនៃគោលគំនិត ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា នៅឆ្នាំ២០២០ | សប្តាហ៍ទី១ ខែ វិច្ឆិកា ឆ្នាំ ២០១២ |
| និយាមនៃបែបបទសំរាប់អនុវត្តការធ្វើតេស្តរកមេរោគអេដស៍ និងផ្តល់ប្រឹក្សា | សប្តាហ៍ទី២ ខែ កញ្ញា ឆ្នាំ ២០១២ |
| និយាមនៃបែបបទសំរាប់អនុវត្តយុទ្ធវិធីជំរុញខ្លាំងក្លាការឆ្លើយតបរួមគ្នា រវាងសេវាថែទាំព្យាបាលជំងឺអេដស៍, សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ និងជំងឺរបេង ដើម្បីលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ លើទារក-កុមារ និងឆ្លងជំងឺស្វាយពីកំណើត នៅប្រទេសកម្ពុជា | សប្តាហ៍ទី១ ខែ តុលា ឆ្នាំ ២០១២ |
| និយាមនៃបែបបទសំរាប់អនុវត្តយុទ្ធវិធីជំរុញខ្លាំងក្លាការ បង្ការ ថែទាំ និងព្យាបាលក្នុងចំណោមក្រុម ប្រជាជនប្រឈមមុខខ្ពស់ | សប្តាហ៍ នៃថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២ |
| និយាមនៃបែបបទនៃយុទ្ធវិធីជំរុញខ្លាំងក្លា នៃការថែទាំបន្ត លើអ្នកផ្ទុកមេរោគអេដស៍ | កំពុងដំណើរការចាប់ផ្តើមពី<br>ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ |
| ឯកសារគោលគំនិតនៃការព្យាបាល សំរាប់បង្ការជាយុទ្ធសាស្ត្រ សំរាប់លុបបំបាត់ ការឆ្លងថ្មីនៃមេរោគអេដស៍ នៅប្រទេសកម្ពុជា | ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១២ |
| បើកយុទ្ធនាការ ការផ្តើមគំនិត កម្ពុជា ៣.០ | កាលបរិច្ឆេទ និងកំណត់នៅពេលក្រោយ |

- **ចាប់ផ្តើមអនុវត្តការផ្តើមគំនិតកម្ពុជា ៣.០ នៅថ្នាក់ស្រុកប្រតិបត្តិ** (ឆមាសទី៤ ២០១២)
- **ឆមាសទី៤ ឆ្នាំ ២០១២ ស្រុកប្រតិបត្តិបាត់ដំបង (មិនមានមេរោគអេដស៍ នៅតាមស្រុកប្រតិបត្តិ សំរាប់អាស៊ាន នៅឆ្នាំ ២០១៥)**
- **ឆ្នាំ ២០១៣: ពង្រីកនៅ ៦ស្រុកប្រតិបត្តិ**
    - ស្រុកប្រតិបត្តិកំពង់សៀម ខេត្តកំពង់ចាម
    - ស្រុកប្រតិបត្តិសៀមរាប ខេត្តសៀមរាប
    - ស្រុកប្រតិបត្តិត្បូង ជើង និងលិច នៅភ្នំពេញ
    - ស្រុកប្រតិបត្តិអូជ្រៅ (រួមទាំងក្រុងប៉ោយប៉ែត) ខេត្តបន្ទាយមានជ័យ
- **ពិនិត្យឡើងវិញនូវវឌ្ឍនៈភាព** (ចុងឆ្នាំ ២០១៣)
- **ពង្រីកទៅទូទាំងប្រទេស នៅស្រុកប្រតិបត្តិដែលមានកំរិតប្រឈមមុខខ្ពស់ ចំនួន ៣២ ស្រុក ចាប់ពីឆ្នាំ ២០១៤**

បញ្ជីក្រុង ឬ ស្រុកដែលមានកំរិតប្រឈមមុខខ្ពស់ នៅកម្ពុជា

| ល.រ | ខេត្ត/ក្រុង | ក្រុង/ស្រុកប្រតិបត្តិ | ក្រុមប្រឈមមុខខ្ពស់ | អត្រាប្រេវ៉ាឡង់ HIV ក្នុងចំណោម ស្រីមកពិនិត្យផ្ទៃពោះ |
|---|---|---|---|---|
| ១ | ភ្នំពេញ | ១.១ ស្រុកប្រតិបត្តិត្បូង (មានជ័យ)<br>១.២ ស្រុកប្រតិបត្តិលិច (ពោធិសែនជ័យ និងដង្កោ)<br>១.៣ ស្រុកប្រតិបត្តិកណ្តាល (ចំការមន និង ៧មករា)<br>១.៤ ស្រុកប្រតិបត្តិជើង (ទួលគោក ឬស្សីកែវ និង សែន សុខ) | EW, MSM, TG, PWID, PWUD | 0.៣៨%<br>0.២៥%<br>0.៤៣%<br>0.៧៥% |
| ២ | បាត់ដំបង | ២.១ ស្រុកប្រតិបត្តិបាត់ដំបង<br>២.២ ស្រុកប្រតិបត្តិសំពៅលូន | EW, MSM, TG,PWUD | 0.១៤%<br>0.៥៥% |
| ៣ | បន្ទាយមានជ័យ | ៣.១ ស្រុកប្រតិបត្តិសិរីសោភណ្ឌ<br>៣.២ ស្រុកប្រតិបត្តិអូជ្រៅ រួមបញ្ចូលក្រុងប៉ោយប៉ែត | EW, MSM, TG,PWUD | 0.៣៣%<br>0.២៧% |
| ៤ | ប៉ៃលិន | ៤.១ ស្រុកប្រតិបត្តិប៉ៃលិន | EW, MSM, TG,PWUD | 0.៤៦% |
| ៥ | សៀមរាប | ៥.១ ស្រុកប្រតិបត្តិសៀមរាប | EW, MSM, TG,PWUD | 0.២៤% |
| ៦ | ឧត្តរមានជ័យ | ៦.១ ស្រុកប្រតិបត្តិសំរោង<br>៦.២ ស្រុកប្រតិបត្តិអន្លង់វែង | EW, MSM, PWUD | |
| ៧ | ព្រះវិហារ | ៧.១ ស្រុកប្រតិបត្តិព្រះវិហា រួម បញ្ចូល សាឯម | EW, MSM, PWUD | |
| ៨ | កណ្តាល | ៨.១ ស្រុកប្រតិបត្តិតាខ្មៅ<br>៨.២ ស្រុកប្រតិបត្តិគៀនស្វាយ | EW, MSM, TG,PWUD | 0.២៧%<br>0.0៥% |
| ៩ | កំពង់ស្ពឺ | ៩.១ ស្រុកប្រតិបត្តិច្បារមន | EW, MSM, PWUD | 0.១៤% |
| ១0 | តាកែវ | ១0.១ ស្រុកប្រតិបត្តិដូនកែវ | EW, MSM, PWUD | 0.១៦% |
| ១១ | កំពត | ១១.១ ស្រុកប្រតិបត្តិកំពត | EW, MSM, PWUD | 0.២៧% |
| ១២ | ព្រះសីហនុ | ១២.១ ស្រុកប្រតិបត្តិព្រះសីហនុ | EW, MSM, PWUD | 0.៦៩% |
| ១៣ | កោះកុង | ១៣.១ ស្រុកប្រតិបត្តិស្មាច់មានជ័យ | EW, MSM, | 0.៣៣% |

| | | | | |
|---|---|---|---|---|
| | | | PWUD | |
| ១៤ | ពោធិសាត់ | ១៤.១ ស្រុកប្រតិបត្តិសំពៅមាស | EW, MSM, PWUD | 0.១0% |
| ១៥ | កំពង់ឆ្នាំង | ១៥.១ ស្រុកប្រតិបត្តិកំពង់ឆ្នាំង | EW, MSM, PWUD | 0.១៥% |
| ១៦ | ស្វាយរៀង | ១៦.១ ស្រុកប្រតិបត្តិស្វាយជ្រុំ<br>១៦.២ ស្រុកប្រតិបត្តិជីភូ/ក្រុងបាវិត | EW, MSM, PWUD | 0.0៤% |
| ១៧ | ព្រៃវែង | ១៧.១ ស្រុកប្រតិបត្តិកំពង់លាវ<br>១៧.២ ស្រុកប្រតិបត្តិអ្នកលឿង | EW, MSM, PWUD | 0.១0%<br>0.១0% |
| ១៨ | កំពង់ចាម | ១៨.១ ស្រុកប្រតិបត្តិកំពង់សៀម<br>១៨.២ ស្រុកប្រតិបត្តិមេមត់ | EW, MSM, PWUD | 0.១៥%<br>0.១0% |
| ១៩ | កំពង់ធំ | ១៩.១ ស្រុកប្រតិបត្តិកំពង់ធំ | EW, MSM, PWUD | 0.១0% |
| ២0 | ក្រចេះ | ២0.១ ស្រុកប្រតិបត្តិក្រចេះ | EW, MSM, PWUD | 0.៣៩% |
| ២១ | ស្ទឹងត្រែង | ២១.១ ស្រុកប្រតិបត្តិស្ទឹងត្រែង | EW, MSM, PWUD | |
| ២២ | រតនគីរី | ២២.១ ស្រុកប្រតិបត្តិរតនគីរី | EW, MSM, PWUD | |
| ២៣ | មណ្ឌលគីរី | ២៣.១ ស្រុកប្រតិបត្តិមណ្ឌលគីរី | EW, PWUD | |
| | សរុប: ២២ខេត្ត ១ក្រុង | ៣២ ស្រុកប្រតិបត្តិ | | |